A-5-6-52
INDOCHINE FRANÇAISE RÉGIE

# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ៣ លេខ ៩

ខែ មិថុនា កក្កដា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥១ - ១៩៥២.

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

ទំព័រ


គុម្ពដ្ឋាន - មធ្យមដ្ឋានទី ២ ភាសា ... ៣

មធ្យមដ្ឋានទី ១ អាទិកដ្ឋាន ភាសា ... ១១

កុមារដ្ឋាន - បរិច្ឆណដ្ឋាន ភាសា ... ២៣

អាទិកដ្ឋាន — មធ្យមដ្ឋានទី ១ — នព្វន្ត — រង្វាស់រង្វាល់
ធរណីមាណសាស្ត្រ ... ៣១

កុមារដ្ឋាន បរិច្ឆណដ្ឋា - នព្វន្ត - រង្វាស់រង្វាល់ ... ៤១

អាទិកដ្ឋាន - មធ្យមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ ... ៤៥

បរិច្ឆណដ្ឋាន - កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ វិធីបង្ការរោគ ... ៥០

លោកនីតិ សំរាប់គ្រូបង្ហាត់ ... ៥២

មេសូត្រត់មាត់ ... ៥៨

# ឧត្តមដ្ឋាន

## ភ្នំពេញ

ភ្នំពេញជាឋានទីមួយល្អប្រសើរនៅប្រទេសឥណ្ឌូចិន ។ កន្លែងឋានទីនេះជាទីស្ដុកស្ដម្ភ នៅចំទន្លេបែកជាបួន ដ៏មានសណ្ឋានដូចលានធំលំអខាងមុខ ។ ពីចំងាយតាមផ្លូវជើងទឹក គេឃើញក្រុងភ្នំពេញលេចឡើងដូចជាផ្ទួរសិលាសក្បុសបម្រុះពណ៌ខៀវស្រងាត់ហាក់ដូចថ្នាំដែលជាងផាត់ ។

កំពូលប្រាសាទខ្ពស់ផុតព្រឹក្សាមានសណ្ឋានដូចមកុដ ។ លុះកាន់តែគេមកជិត ទើបគេឃើញក្រុងភ្នំពេញរីកឡើងបន្តិច ៗ ម្ដងគេសំគាល់ច្បាស់នូវវត្ថុនានា ។ នោះប៉ែកខាងត្បូងឬខាងស្ដាំភាពបែបសំដែងឡើងឲ្យគេស្គាល់ជាក្រុងខ្មែរដ៏ហើយនូវប្រាសាទមានដំបូល ក្បូរផ្ទុកស្រទាប់តម្រួតលើគ្នាជាហ្វាល្អក់នៅចុងដំបូលដូចជាប្រមោយហោជាង មានពងជាត្រីកោណ ប្រកបទ្រូវក្បីវល្លិ៍លេចស្លឹកផ្កាផ្តែលរពាក់ព័ន្ធរកិបរកុបជាល្បតពស់គ្មានទាស់ក្លែក ។ កំពូលដោលទៅលើមានសណ្ឋានជាមកុដដែលជាប្រធាននៃក្បាច់រចនាខ្មែរ ទីត្រង់នេះឯងជាវាំងហ្លួង ។ បន្ទាប់ពីនោះប៉ែកទៅខាងជើងព្រះបរមរាជវាំង គេឃើញតែផ្ទះថ្មសព្រោងដ៏មានថ្នាក់ជាន់សង់ជាផ្លូវរងវែង ៗ ដូច ៗ គ្នាសន្ធឹងបែរមករកមាត់គង្គា ដែលកាត់

ខ្វែងគ្នាជាក្រឡាចត្រង្គជាផ្ទាំងផ្ទះនៅគ្រប់ក្រឡា ៗ នោះខ្សែបរិវេណក្រៅចម្ងាយកន្លះគីឡូម៉ែត្រពីឯជើងទៅត្បូងទទឹងមួយគីឡូម៉ែត្រពីឯកើតទៅឯលិច ទីក្រុងហ្នឹងឯងជាផ្សារដ៏មានមនុស្សទៅខ្វល់រវើមរវាមនូវយានជំនិះដែលត្រាច់ទៅមកពុំដែលដាច់ ៗ ហួសពីដំបន់នេះទៅខាងជើងទៀតគេឃើញផ្ទះស្រឡះមួយ ៗ សង់ទីងថ្មតាមរបៀបសម័យដ៏មានកំពែងព័ទ្ធជុំវិញលំអទីងសួនច្បារដែលក្រោះតូចធំបេះ តែស្រស់ញញឹមខ្ពុះខ្ពស់ស្រោងស្រឹងឲ្យមូបត្រៃឈើគួរជាទីដំរេកឲ្យបង់នៅ ៗ នៅចំកណ្ដាលដំបន់នេះគេឃើញកុំតូចមួយមានស្តូបលេចចេញខ្ពស់ត្រដែត ផុតអំពីគ្រិះស្ថានបណ្ដាលឲ្យមានសេចក្ដីស្រងេះស្រងោចក្នុងចិត្ត ៗ តំបន់ហ្នឹងហើយជាទីគ្រប់គ្រងរក្សាស្រុក ៗ ពីនោះតទៅគេឃើញភូមិអ្នកស្រុកពុំអស់ពុំហើយមានផ្ទះសង់ហែតាមក្បែរមាត់ទន្លេដ៏មានពណ៌ខៀវស្រងាត់ ៗ តាមក្បែរទន្លេ មាននាវាចតខ្វាន់ខ្វាប់ដងក្ដោងប្រូងប្រាងបំពង់ភ្លើងបង្ហុយផ្សែងគួរឲ្យមានទស្សនាគេហោង ៗ សេចក្ដីសំរាំង-ច-ឈុំ

ស្តុតាស្តម្ភៈ គុ-មាំមួន ជព្វារៈ ន. ឈ្មោះគ្រឿងរចនាមួយយ៉ាងសំរាប់គាក់តែងដំបូលប្រាសាទ ចត្រង្គៈ ន. ក្លាយមកពីសំ- ម. ថា. ចតុរង្គ "មានអង្គ ៤" ឈ្មោះល្បែងមួយយ៉ាងមានកូន ៣២ សម្រាប់លេងដើរលើក្ដារ ៤ ជ្រុងមានក្រឡា ៦៤ ៗ

អក្ខរាវិរុទ្ធ= ស្តម្ភ (ម្ភ) ផ្លូវ (វ) ក្បួស (ស) ប្រាសាទ (ទ) មកុដ (ដ) ភាព (ព) បញ្ញា (ញ្ញា) បត្រង្គ (ង្គ) បរិវេណ (ណ) ព័ទ្ធ (ទ្ធ) ក្បែរ (រ)

សួរចាំង.– រាជធានីកម្ពុជាស្ថិតនៅកន្លែងណា ៗ គេមើលពីចម្ងាយទៅឃើញអ្វីជាមុន ៗ ព្រះរាជវាំងនៅប៉ែកខាងណានៃក្រុងភ្នំពេញ ៗ ល ៗ

## ក្រុងអង្គរ

កាលក្នុងកំឡុងសតវត្សរ៍ទី ៩ និងទី ១៣ នៃគ្រិស្តសករាជក្រុងកម្ពុជា ៗ ដែនមួយគបដោយបុណ្ណានុភាពខ្លាំងណាស់ ៗ ខេមរៈជាតិជាន់នោះ បានកសាងសេនាសនៈដ៏ល្អ ៗ គួរស្ញែង ៗ ក្រោយមកខ្មែរ ៗ បែកខ្ញែកពពួនគ្នាទៅប៉ែកកម្ពុជាខាងត្បូង ដោយទ័ពសៀមលុកលុយជាន់យកក្រុងអង្គរ គុហាសនៈដ៏ប្រសើរទាំងនោះក៏បោះបង់ចោលជាកន្លែងដែលព្រៃទន្ទ្រានលុបទៅ អ្នកប្រទេសអឺរុបទើបបានឃើញថ្វីដៃអស្ចារ្យនៃខ្មែរ ដែលរលត់បាត់មកជាយូរអង្វែងហើយដោយហេតុនោះ ៗ លុះដល់មកគ្រិស្តសករាជ ១៩០៧ ក្រុងទេពបានបង្វែរអង្គរមកក្រុងកម្ពុជាវិញ ទើបរាជការឲ្យកាប់គ្រាយព្រៃដែលរួតរឹតប្រាសាទដ៏ធំ ៗ ខ្លះបានលេចចេញរូបរាងប៉ុណ្ណឹងឡើង ៗ បណ្តាសេនាសនៈខ្មែរបុរាណប្រាសាទអង្គរ

វត្តនៅគង់ទ្រង់ទ្រាយគ្រាន់បើជាងសេនាសនៈទាំងអស់ ៗ គេមានចិត្តស្មែងនឹងថ្មល់ល្អស្អាតផងហើយនូវកំពូលថ្មលំអនឹងគុហាតូច ៗ តាំងនៅដោយអន្ទើ ៗ តាមថ្នល់រហូតដល់ប្រាសាទដែលកើតឡើងពីភេងទេងតម្រួតជាថ្នាក់ ៣ ជាន់ ទ្រូកំពូលខ្ពស់តាំងប្រាំក៏មានសណ្ឋានដូចមកុដល្អប្រសើរ ៗ គេឃើញតែថ្មបាក់បែកនៃខ្លួននាគរចនាជាបង្កាន់ដៃ ភ្ជាប់លើដើងទៀន ក្បាលនាគងើតឡើង មានសណ្ឋានដូចផ្ចិតបើក ៗ នៅជញ្ជាំងភេងទេង មានក្បាច់ចម្លាក់រើករណ្ដាជាវៀងព៌រ ដែលយើងត្រិះរិះទៅ យើងអាចឃើញទំនៀមទំលាប់ ពីបុរាណដូចម្ដេច ៗ នៅខ្លោងទ្វារមានចំឡាក់រូបទេពអប្សររាំលូតល្វៃ ៗ

មានប្រាសាទ ច្រើននៅក្នុងទីអង្គរធំដែលជាភាពនិវេសន៍ចាស់ ៗ នៅនោះមានព្រះផំណាក់ ដូចប្រាសាទបាយ័នដ៏មានកំពូលមុខព្រហ្មញញឹមអស់កប្បកល្បឈមទៅមហាទិសទាំងបួន ៗ ប្រាសាទខ្លះនៅគប់បាត់ក្នុងព្រៃនៅឡើយ ខ្លះលេចចេញបន្តិចបន្តួចដោយគេកាប់ឆ្កា ខ្លះមានទំហំសម្បើម ប៉ុន្តែប្រាសាទទាំងអស់នោះសឹងជាសាងដោយលទ្ធិសាសនា ៗ ប្រាសាទអង្គរជាប្រាសាទល្អវិសេសមួយក្នុងលោក ៗ

(សេចក្ដីសំរាំង ច. ឈុំ)

## ពន្យល់ពាក្យ

សតវត្ស = កាលកំណត់មួយជុំរយឆ្នាំ · មួយខួបរយឆ្នាំ ៗ

សេនាសនៈ (ម.ថ. សេនាសៈនៈ) ន. ទីដេកអង្គុយ

គុហា= (ម.ថ. គុហា៎) -ន. រូងធំដែលកើតឯងក្នុងភ្នំ

ក្រុងទេពៈ= ថៃឡង់ឌ៍ -ប្រទេសសៀម ។

រោងធំ= រោងវែងជាបរិវេណ ព័ទ្ធជុំវិញប្រាសាទឬព្រះវិហារ ជាដើមមានទ្វារធំទាំង ៤ ទិស ។

ស្រីទេពអប្សរ= ស្រីមានសម្បុរស្រស់ផូរផង់ ស្រីសួគ៌

និវេសន៍= ទីសំរាប់នៅ ។ ព្រះរាជនិវេសន៍=ព្រះរាជដំណាក់ ។

បាយ័ន= ឈ្មោះប្រាសាទថ្មបុរាណមួយក្នុងកំពែងនគរធំ ។

គាប្បគាល្ប=(ម.ថ.កាប់កាល់) កាលដែលតាំងនៅយូរអង្វែង ។

---

## មជ្ឈិមដ្ឋានទី ២

## ស្ពានមុនីវង្ស

នៅវេលារថយន្តបត់វង់ ក្នុងតាមផ្លូវកោងកាត់ភូមិច្បារអំពៅសំដៅ ទៅទីក្រុងភ្នំពេញ បើអ្នកដំណើរ ងាកមើលទៅខាងលិចនឹងជាប់ភ្នែកទៅ លើត្បូងរបស់មួយសទុង ដែលលេចចេញផុតពីចុងព្រឹក្សាទាំងឡាយៗ របស់នោះហាក់កាន់តែរីកទឹងខ្ពស់ឡើង នៅវេលាដែលគេកាន់តែទៅជិត អ្នកដំណើរដែលពុំសូវធ្លាប់ស្គាល់ទីក្រុង មិនសូវធ្លាប់ឃើញរបស់ចំឡែក

ថ្មី ៗ កើតមានសេចក្តីរំភើបក្នុងចិត្ត ដ្បិតឆ្ងល់នឹងតួចំឡែកនោះ ដូនកាល លេចឡើងជាសណ្ឋានដំបូលស្រួចខ្ពុំ ដូនកាលវែងរពើតរពើង ឧបមា ដូចជានាគមួយធំសម្បើម ៗ សេចក្តីសង្ស័យរលត់បាត់មួយរំពេច ដោយយល់ដាក់ថាជាស្ពាន គឺស្ពានមុនីវង្សដែលរាជការបានសង់រួចមកជាងម្ភៃឆ្នាំហើយ ស្ពាននេះវែងបណ្តោយបីរយម៉ែត្រ សង់កាត់ទទឹងទន្លេ ទប់ទល់តនឹងទឹកហូរខ្លាំងកួចត្របាញ់ក្នុងរដូវវស្សា ៗ ស្ពាននេះបំពោងទ្រនុងកណ្តាល មានភាពជាស្នាមួយធំក្រៃលែងដែលយិតកោងមកហើយដោយដៃព្រានព្រៃដ៏មានបុទ្ធិ ៗ ដំបូលកណ្តាលខ្ពស់លលៃ ហាក់នឹងសង្កត់ស្ពានទាំងមូល ទំលាក់ទម្ងន់ទៅលើបុងសងខាងឲ្យជ្រែងជាប់នៅ ៗ របស់ទាំងអស់ដែលកាត់ខ្វែង ទាញទង់យិតយោងទប់កម្លាំងគ្នាទៅវិញទៅមក ៗ បណ្តោយស្ពានចែកជាបីសង្កាត់ កណ្តាលធំទូលាយសំរាប់ឲ្យយានជំនិះផ្សេង ៗ បើកបរ សងខាងជាផ្លូវសំរាប់ឲ្យអ្នកថ្មើរជើង មានបង្កាន់ដៃជារបាំង ៗ គេនឹកអស្ចារ្យនឹងទម្ងន់ដែកធំម៉ឹង ៗ ដែលអាចលើកដាក់ផ្គងផ្គុំគ្នាឡើង ជាតួស្ពានមួយយ៉ាងសម្បើមយ៉ាងល្អឯកនៅស្រុកខ្មែរ ៗ គឺដោយហេតុតែស្ពាននេះហើយ ដំណើរទៅមកនៃអ្នកស្រុកខាងត្រើយភ្នំពេញនឹងអ្នកខាងត្រើយឆ្វេង នៃទន្លេបាសាក់ធ្វើបានដោយស្រួល ស្ពាននេះជារបស់មានប្រយោជន៍យ៉ាងសំខាន់ ដល់ការដឹកនាំផលប្រយោជន៍

ក្នុងស្រុក ឬក្រៅស្រុកចូលទៅទីក្រុងភ្នំពេញ ។

(សេចក្ដីសំកាំង ប. ឈុំ)

## ពន្យល់ពាក្យ

សទ្ទុង= ស្ដួសវែង

រពើតរពើង= ដំបូលស្ពានមិនស្មើ គឺខ្ពស់អាបខ្ពស់ទាប ។

ឫទ្ធិ = (ម. ថ. រិត) ន. អំណាច

លវែ= ដែលវែងស្រលួត

ផលប្រយោជន៍= ទំនិញឬធនធានកើតឡើងពីព្រះធរណី....

វេវចនៈ= ភាព= បែបបទ-លំនាំ-ឫកពា-សណ្ឋាន-ទ្រង់ទ្រាយ ។

សទិសសព្ទ: លេចកិ. លេចសំដី ។ លេចគុ. ភ្លមលេច ។ លេចន. ដំណៅលេច ។ លិចកិ. ថ្ងៃលិច ។ លិចន. ទិសខាងលិច។

អក្ខរាវិរុទ្ធ = រថ (ថ), នាគ (គ), ហូរ (រ), វិស្សា (ស្សា) ឫទ្ធិ (ទ្ធិ) ច្មើរ (រ) ។

## ចេតិយភ្នំពេញ

ទស្សនាអំពីចម្ងាយមកទីក្រុងភ្នំពេញ យើងឃើញស្តូបមួយខ្ពស់ផុតទីព្រឹក្សា ទីងគេហដ្ឋានទាំងឡាយ សញ្ញាញុំាងយើងឲ្យដឹងថាហ្នឹង ហើយជាក្រុងភ្នំពេញ ។ សេចក្ដីទុក្ខមេញក្នុងដំណើរកើរសាយ បង្កើតសេចក្ដីរីករាយចង់តែស្រួតរូតឲ្យឆាប់ដល់ ។

ព្រះចេតិយ ពន់ស្តុកស្តម្ភ ទំហំសមនឹងកំពស់ប្រហែលសាមសិប ម៉ែត្រដោយប្រមាណ ។ តួអង្គធំកំភាយ គាយស្រួលជាទ្រង់ផ្កាត្រកួន គង់លើបល្ល័ង្ក តាំងជាទ្រនាប់ខ្សាច់បីជាន់ ដ៏មានជ្រុងសរពើស្បូត្រទំ សង្កត់លើក្បួបមួយ ៗ ពីលើអង្គមានកំពូលដោលទៅលើរៀវស្រួល ស្រួចតាលជាច់ ចេនាជាក្បាច់រូតកន្ទុតបំផុតនឹងត្រយូងចេកឡើងទឹងឈើ តាត្រៅ ។

តាំងពីគាត្តុតលូតលា រហូតមកដល់យើង ស្តូបនេះនៅតែឈរខ្ពស់ត្រដែត ដ៏មានទំហំធំសមល្មមមានបុគ្គានុភាពលើទីក្រុងក្នុំពេញ ៗ ដោយទំនាយនៃស្រុកនឹងបានស្តូបនេះ ជាមង្គលអ្វីមួយបណ្ដាលឲ្យពន្ធការរៀបតុបតែងក្នុងភព្វព្រះបាទសម្ដេចព្រះនរោត្តម ។ ព្រះវិហារកសាងឡើងដោយឥដ្ឋ គ្រឿងឈើប្រក់ក្បឿងមានដំណើរកាច់ចេនារូបនាគជាបង្កាន់ដៃតាមរបៀបអង្គរ មានមាគាំពន្ទវិលវ័ណ្ណដល់កំពូលក្នុំ ទីងសួនច្បារនូវរុក្ខជាតិនានា មានទ្រង់ចិញ្ចឹមសត្វព្រៃ គឺបក្សាបក្សីនូវចតុរង្គសត្វ ម្រឹគាម្រឹគី ព្រះវិហារនឹងសួនច្បារសឹងជាបរិវារ លំអព្រះចេតិយក្នុំពេញ ដ៏ជាគោលចារិក តែងបង្កើតសិរីសួស្ដីមង្គលដល់ស្រុកខ្មែរនេះឯង ។

សេចក្ដីសំរាង ប. ឈុំ

ឧស្សនា= ការឃើញ ៗ ស្តូប = ន. ទីឋានធ្វើដោយឥដ្ឋ ឬថ្ម

សម្រាប់បញ្ចុះធាតុ គេហដ្ឋាន ឬ គេហស្ថាន= ន. ផ្ទះនានា ចេតិយ= ទីដែលគេគោរពបូជាដូចដើមឈើធំក្តី មានថ្មធំក្តី គេសន្មត់ទុកថាជាសក្តិសិទ្ធិគេតែងធ្វើសក្ការបូជា គោរពក៏ហៅថាចេតិយទាំងអស់ ៗ

ស្តុកស្តម្ភ= រឹងមាំមួន សរពើស្ត្រ ឬ សារពើស្ត្រ= ន. ការរចនាមួយបែបមានសណ្ឋានរបត់ញោចជាបីជ្រុង ៗ ទរដ្ឋសត្វ ន, សត្វលូន

សួរហោះ អ្នកសំគាល់ទីក្រុងភ្នំពេញពីចម្ងាយដោយសារអ្វី? ៗ ព្រះពជធាទីភ្នំពេញនៅត្រង់ណា? ៗ ស្តូបនោះគេបានរៀបតុបតែងក្នុងពជ្រក្សត្រិយ៍ណា ៗ ស្តូបនឹងចេតិយខុសគ្នាដូចម្តេចខ្លះ? ៗ

---

## មជ្ឈិមដ្ឋានទី ២

### រៀនមើល - ហាត់ភាសា

### រឿងត្មាត ឆ្មានឹងបក្សី

នៅក្បែរត្រើយទន្លេគង្គា មានជ្រៃមួយដើមធំ មែកត្រសុំត្រសាយ សាខាធំហើយដោយព្រាន់ជាទីអាស្រ័យនៅនៃបក្សីនិងត្មាតមួយ ៗ ដោយ

កម្មអាក្រក់ឲ្យផល គ្នាគនោះក៏ទៅជាខ្វាក់ងងឹតងងល់ ក្របករបេរិលអស់រលើង ៗ បក្សីជាតិទាំងឡាយដែលអាស្រ័យនៅនាដើមជ្រៃនោះ មានចិត្តអាណិតអាសូរ តែងរំលែកចែកអាហារខ្លួនបន្តិច ៗ ម្នាក់ឲ្យដល់គ្នាគនោះ ជួយចិញ្ចឹមឲ្យមានជីវិតរស់នៅ ៗ

គ្រានោះមានឆ្មាមួយ ចូលមករកចាប់កូនបក្សីស៊ីជាអាហារ នៅក្នុងព្រៃឈើនោះ ៗ កូនបក្សីទាំងឡាយកាលឃើញឆ្មាដើរចូលមក ក៏កិតភ័យរន្ធត់រត់ខ្ចេខ្ចាកោលាហលពេញទាំងព្រៃ ៗ គ្នាគបានឮសូរសម្លេងអឺងកងខ្ទៀវខ្ចាវដូច្នោះក៏ស្រែកសួរទៅថា ៖ ‘‘អាណាមកធ្វើអ្វីឲ្យជ្រួលច្របល់របល់ដូច្នេះ? ,, ឆ្មាសម្លឹងមើលទៅឃើញគ្នាគក៏តក់ស្លុតញាប់ញ័រក្នុងចិត្ត ហើយគិតថា ៖ “ឱអាគ្នាអញដល់គ្រោះស្លាប់ហើយតើ” តែថាជរាបណាក្តីភយន្តរាយមិនទាន់មកដល់ទេ, ជរាបនោះ បុគ្គលគប្បីប្រុងប្រយ័ត្នដល់ភ័យនោះ បើក្តីភយន្តរាយមកដល់ហើយ បុគ្គលគប្បីក្លាហានតស៊ូនឹងភ័យនោះ តាមគំនិតខ្លួនដែលបានគិតទុកមុនស្រេចហើយ ៗ

ឥឡូវនេះ អាគ្នាអញចូលមកខកខ្លួនដល់ជិតក្តីស្លាប់ហើយ នឹងថយទៅក្រោយវិញក៏មិនបាន, ណ្ហើយចុះបើមានហេតុយ៉ាងណាកើតឡើងក៏តាមការណ៍ចុះអាគ្នាអញនឹងចូលទៅឲ្យដល់គ្នាគ វ៉ៃអែបឲ្យស្និទ្ធស្និទ ៗ ឆ្មាកេខបាយឃើញដូច្នេះហើយក៏ចូលទៅជិតគ្នាគពោលពាក្យសំពះសួរថា

"បពិត្រលោកម្ចាស់, ខ្ញុំបាទសូមជំរាបសួរ" ។ ត្មាតសួរថា "ឯងជាអ្វី?" ឆ្មាឆ្លើយតបថា "ខ្ញុំបាទជាសត្វឆ្មា" ត្មាតគំហែងថា "នែសត្វចង្រៃ ចូរថយចេញឲ្យឆ្ងាយទៅ បើមិនថយចេញទេ អាឯងត្រូវគ្រោះស្លាប់ឥតឡូវមិនខាន" ។

ឆ្មានិយាយអង្វរថា "សូមលោកស្ដាប់ពាក្យខ្ញុំបាទសិនកាលបើឃើញថាគួរសម្លាប់ ខ្ញុំបាទក៏សុខចិត្តទទួលស្លាប់ឥតប្រកែក" ។

## អាននិងពន្យល់ពាក្យ

ភយន្តរាយ = (ភ័យយ័នត:រ៉ាយ) ន. អន្តរាយដែលគួរខ្លាច, អន្តរាយយ៉ាងសម្បើម ។

ជ្រៃ = ឈ្មោះឈើមានដើម ពួកពោធិ ពួកល្វា មានពួររយើករយាក ប័ត្ធព័ន្ធ ជ្រៃមានច្រើនយ៉ាង គឺជ្រៃពោធិ ជ្រៃក្រឹម ជ្រៃលៀប ជ្រៃត្រាង ។

ព្រង់ = ន. រន្ធ, ប្រហោង: ព្រង់ផាស ។

ត្មាត = ន. ឈ្មោះសត្វស្លាបធំ បរិភោគសាកអសុភជាអាហារ

កោលាហល = (ម. ថ. កោឡាហល់) ន. សេចក្ដីភ្ញាក់ផ្អើល, ជ្រួលច្រើម ។

## រឿងត្មាត, ឆ្មា និងបក្សី (តបប់)

ត្មាតស្ដាប់ហើយនិយាយថា « មើលនិយាយមកមើល អាឯង

ចូលមកនេះត្រូវការរកអ្វី ? >> ។ ឆ្មាឆ្លើយថា ខ្ញុំបាទនៅត្រើយទន្លេ គង្គានេះឯង ប្រព្រឹត្តព្រហ្មចរិយធម៌ ជាប្រក្រតីមិនហ៊ានស៊ីសាច់ឈាម-ទេ ខ្ញុំបាទបានឮហ្វូងបក្សីជាតិសរសើរកិត្តិគុណលោក ចំពោះមុខខ្ញុំបាទជារឿយៗ ថាលោកជាអ្នកចេះដឹងច្រើន ចិត្តដន់ក្នុងធម៌ល្អ ទុកចិត្តស្និទ្ធស្នេហាយកជាវិស្សាសៈបាន ហេតុនេះបានជាខ្ញុំបាទមានចិត្តត្រេកអរចង់ចូលមកគ្រង់ក្រាប់ស្តាប់ធម៌ រៀនវិជ្ជាច្បាប់គតិលោក គតិធម៌ អំពីសំណាក់លោកដែលជាបុគ្គលចាស់ព្រឹទ្ធាចារ្យ មានការចេះដឹងស្កាត់ជំ-នាញ ប្រសប់ប៉ិនប៉ាក្នុងវិជ្ជាផ្សេងៗ ហេតុអ្វីក៏លោកបែរទៅជារករឿងកាប់សម្លាប់ខ្ញុំបាទដែលជាភ្ញៀវទៅវិញ, ព្រោះជាបុគ្គលគប្បីធ្វើបដិសណ្ឋារចំពោះភ្ញៀវ ទោះបីភ្ញៀវនោះជាសត្រូវដែលមកដល់ផ្ទះហើយ ដូចព្រឹក្សាជាតិតែងឲ្យម្លប់ជាទីសំចតមិនរើសមុខ សូម្បីអ្នកកាប់ឈើក៏ដោយ, ម្យ៉ាងទៀតភ្ញៀវវិលត្រឡប់ចេញពីផ្ទះអ្នកណាដោយក្ដីក្ដៅក្រហាយចិត្ត ភ្ញៀវនោះឈ្មោះថាប្រគល់ឲ្យនូវបាបអប្បមង្គលដល់អ្នកម្ចាស់ផ្ទះនោះ ។

ត្មាតនិយាយកាត់ថា : << ឲ្យតែឈ្មោះថាឆ្មាហើយ សុទ្ធតែចូលចិត្តស៊ីសាច់នៅជាអាហារទាំងអស់ នៅក្នុងព្រៃដើមជ្រៃនេះ មានសុទ្ធតែបក្សីអាស្រ័យនៅ ហេតុនេះបានជាអញហាមឃាត់យ៉ាងនេះ >> ។

ឆ្មាស្ដាប់ពាក្យត្មាតហើយ ក៏ស្រពោនទន់ដាក់មុខ យកជើងមុខ

ស្ទាបត្រចៀកទាំងសងខាង ក្រាបសំពះនិយាយបញ្ជាក់ថា ខ្ញុំបាទបាន សិក្សាគម្ពីរធម្មសាស្ត្រចប់អស់ជើងហើយ រួមសេចក្ដីមកនៅត្រឹមតែមួយ-មាត់គឺ "អហិំសា" ការមិនបៀតបៀនគេ ជាធម៌ប្រសើរក្រៃលែង ។

កាលបើឆ្មានិយាយបន្ទន់ចិត្តត្មាត ឲ្យជឿជាក់ដោយប្រការផ្សេងៗ-ហើយ ក៏សសៀរចូលទៅក្នុងព្រៃនោះបាន ក៏តាំងតែចាប់កូនបក្សី យកមកហែកស៊ីរាល់ៗថ្ងៃ ។

ឯបក្សីទាំងឡាយដែលឆ្មាស៊ីកូន ក៏យំសោកខ្សៀវខ្សា ប្រជុំគ្នាស៊ើប សួររកដំណើរដើមទងនៃការបាត់បង់កូន ។ ឯឆ្មាលុះបានដឹងរឿងនោះ-ហើយ ក៏បោលចេញពីព្រៃជ្រៅទៅខាងក្រៅភ្លាម បក្សីទាំងឡាយ បបួលគ្នាគយគន់មើលប្រទះឃើញតែឆ្អឹងកូននៅក្នុងព្រៃដើមជ្រៃនោះ ក៏ចោទប្រកាន់ត្មាតចាស់នោះថា « ត្មាតខ្វាក់កញ្ចាស់នេះឯងដែលស៊ីកូន របស់យើង » ទើបព្រួតគ្នាសម្លាប់ត្មាតចាស់ចោលបង់សៀតឮដ៏កាល នោះទៅ ។

## អាននិងពន្យល់ពាក្យ

ព្រហ្មចរិយធម៌ = ( ម.ថ ព្រំមៈចរិយៈធ័រ ) ន. ការប្រព្រឹត្ត ដ៏ប្រសើរ ។

វិស្សាសៈ = ( ម ថ. វិសសាសៈ គុ. ដែលជាទីស្និទ្ធស្នាល ។

បដិសណ្ឋារ = ( ម.ថ. បៈដិសន់ថ៉ារៈ ) ន. ការទទួលរាក់ទាក់ ។

ធម្មសាស្ត្រ = ( ម.ថ. ធ័មៈសាស ) ន. ឈ្មោះគម្ពីរមួយដែលមានសេចក្តីសំដែងអំពីយុត្តិធម៌ ។

អហឹសា = ( ម.ថ អៈហឹងសា ) ន. ការមិនបៀតបៀន ។

គ្នាតបង់ជីវិត ព្រោះគប់មិត្រអាក្រក់ ដូចមានភាសិតបូរាណ ថា៖

កុំទុកចិត្តបរទេស កុំទុកចិត្តអកិនៃស្ត្រម៍ កុំទុកចិត្តអកិប្រាយ..... ។

( សាស្ត្រាច្បាប់ត្រីនេត្រ ) ។

---

# ភាពិកផ្ទុន

## បង្រៀនពាក្យនឹងភាសា

### អាទិត្យទី ១ អំពីពេលវេលា

នាម= ថ្ងៃ, យប់, អាទិត្យ, ខែ, ឆ្នាំ, មួយរំពេច, មួយស្របក់, ម៉ោង, នាទី, (មីនុត) វិនាទី, (សឺកុង)

គុណនាម— ភ្លឺ, ងងឹត, យូរ, ឆាប់, រហ័ស, យឺត, ឆ្នាំចាស់, ឆ្នាំថ្មី, ខែមុន, ខែក្រោយ, ដើមខែ, ចុងខែ, ។

កិរិយាសព្ទ= ខាតពេលវេលា, កត់ខែ, ថ្ងៃ, ឆ្នាំ, រាប់ខែ-ថ្ងៃ-ឆ្នាំ, មើលម៉ោង-នាទី, ថ្ងៃរះ, ថ្ងៃលិច, ៗ

**ហាត់ភាសា** ដែលហៅថាពេលវេលានោះគឺអ្វី? ក្នុង១ឆ្នាំមានប៉ុន្មានខែ? គឺខែអ្វីខ្លះ? ខ្មែរយើងរាប់ឆ្នាំជាប៉ុន្មាន? គឺឆ្នាំអ្វីខ្លះ? ក្នុងមួយអាទិត្យមានប៉ុន្មានថ្ងៃ? គឺថ្ងៃអ្វីខ្លះ? ក្នុងមួយខែមានប៉ុន្មានថ្ងៃ? ក្នុងមួយថ្ងៃមួយយប់មានប៉ុន្មានម៉ោង?

## បង្រៀនមើល

### អំពីពេលតាមរបៀបខ្មែរ

(សៀវភៅវគ្គស្វាធ្យាយន៍បរិច្ឆណាផ្ទានទំព័រ១០៨)

កែតម្រូវ= អាសដ្ឋ= អស្សុជ ៗ បឋមសាធ= បឋមាសាធ

## សរសេរតាមសូត្រ

### អំពីពេលវេលា

ដែលហៅថាពេលវេលានោះ គឺគេសម្រេចយកតាមកំណត់ដំណើរ

ព្រះធរណីវិលជុំវិញខ្លួនឯង ហើយនឹងវិលក្រឡឹងជុំវិញព្រះអាទិត្យផង ។ ពេលដែលព្រះធរណីវិលបានមួយជុំខ្លួនឯងនោះ ហៅថាមួយថ្ងៃមួយយប់ គឺម្ភៃបួនម៉ោង លុះព្រះធរណីវិលបានមួយជុំព្រះអាទិត្យ ទើបហៅថាមួយឆ្នាំ ។ មួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ឬហាសិបពីរអាទិត្យ ។

ដែលហៅថារដូវនោះ គឺកន្លងកំឡុងដែលខ្យល់អាកាសផ្លាស់ប្តូរក្នុង ១ ឆ្នាំ ៗ ។

សរសេរពាក្យពិបាក ដំណើរ - ព្រះធរណី - ព្រះអាទិត្យ - ម្ភៃ ហុកសិបប្រាំ - ហាសិបពីរ - ខ្យល់ផ្លាស់ប្តូរ

## តែងសេចក្តី

ចូរអធិប្បាយអំពីអ្នកប្រើពេលវេលាដូចម្តេច តាំងពីព្រលឹមរហូតដល់ព្រលប់ ។

### ទំនងតែង

តាំងពីព្រលឹមរហូតដល់ពេលបាយ អ្នកធ្វើអ្វីខ្លះ ? ចុះពេលល្ងាចទល់នឹងព្រលប់អ្នកធ្វើអ្វីទៀត ?

## អក្សរផ្ចង់

បង្រៀនសរសេរអក្សរ "មូល, ឬខម"

## អាទិត្យទី ២.– អំពីខ្យល់

នាម.– ខ្យល់, ខ្យល់កើយ, ខ្យល់ដំនោរ, ខ្យល់ព្យុះ, ព្យុះសង្ឃរា, ខ្យល់កំបុតត្បូង (ខ្យល់កួច) ខ្យល់ពីទិសឯជើង

គុណនាម.– រហើយត្រសៀក, ត្រជាក់, រងា តិច ខ្លាំង រំភើ, ខ្លាំងអស្ចារ្យ ។

កិរិយាសព្ទ.– ខ្យល់បក់តិច ៗ, ខ្យល់បក់ខ្លាំង, ខ្យល់កួចធូលី, ខ្យល់រលំរំលើងដើមឈើ, បង្ហោះខ្លែង, បើកក្ដោង ។

## បង្រៀនមើល

ខ្យល់បក់មកពីទិសខាងជើង

(សៀវភៅវិជ្ជាខេមរភាសាបរិច្ឆេទណាផ្លូនទំព័រ ៦៤)

## សរសេរតាមសូត្រ

### អំពីខ្យល់

កាលណាយើងឈរឬអង្គុយនៅកណ្ដាលទីវាល ហាក់ដូចជាមានធម្មជាតិអ្វីមកប៉ះពាល់ខ្លួនយើងឲ្យល្ហើយ ធម្មជាតិនេះហៅថាខ្យល់ ។ ឯស្លឹកឈើដែលកំរើកទៅមកបាន នោះគឺខ្យល់បក់ ។ ខ្យល់បក់នេះជួនខ្លាំង ជួនតិច ខ្យល់បក់តិច ៗ ហៅថាខ្យល់ជំនោរ ខ្យល់បក់ខ្លាំងហៅ-ថាព្យុះ កាលណាខ្យល់នោះបក់ខ្លាំងអស្ចារ្យ ហៅថាព្យុះសង្ឃរា ។

ខ្យល់ព្យុះអាចធ្វើឲ្យដើមឈើ ផ្ទះសម្បែង ទូក កប៉ាល់ វិនាសអន្តរាយបាន ។

ខ្យល់មានប្រយោជន៍ ដើម្បីឲ្យអ្នកដើរទូកសំពៅ បើកក្ដោងលឿនទៅបានដោយងាយ ។

សរសេរពាក្យពិបាក.— ធម្មជាតិ - ខ្យល់ - ល្ហើយ - វាល - ព្យុះសង្ឃរា - វិនាសអន្តរាយ - អស្ចារ្យ - កប៉ាល់ - លឿន

## តែងសេចក្ដី ១

ចូរអធិប្បាយអំពីខ្យល់ព្យុះតាមពាក្យចោទខាងក្រោមនេះ ៖

យ៉ាងដូចម្ដេចដែលហៅថាខ្យល់ព្យុះ ? នៅក្នុងរដូវណាដែលច្រើនមានខ្យល់ព្យុះ ? - ខ្យល់នោះបក់ពីទិសឯណា ? - មុននឹងមាន ខ្យល់នោះ អ្នកសំគាល់ឃើញមានហេតុអ្វីនៅលើមេឃ ? - វេលាខ្យល់នោះបក់មកអ្នកឮស្នូរដូចម្ដេចខ្លះ ? អ្នកឃើញមានអ្វីមកជាមួយផង ? - ខ្យល់នោះបណ្ដាលឲ្យមានហេតុដូចម្ដេចខ្លះ ? - នៅក្នុងភូមិអ្នក នៅក្នុងទន្លេ ? អ្នកចូលចិត្តនឹងខ្យល់នោះឬទេ ? ព្រោះអ្វី ? ។

## បង្រៀនពាក្យនិងភាសា

### អាទិត្យទី៣.— អំពីភ្លៀង

នាម — ភ្លៀង, ផ្គរ, រន្ទះ, ផ្លេកបន្ទោរ, ឥន្ទធនូ, សន្សើម, គ្រាប់ភ្លៀង, ទឹកភ្លៀង ។

គុណ. ច្រើន, តិច, ស្រិចៗ ប្រុយៗ, ទទឹក, ជោក, សើមៗ

កិរិយា.– រាំងភ្លៀង, ភ្លៀងស្រក់តក់ៗ, ទឹកភ្លៀងដក់, ទឹកភ្លៀងជ្រាបទៅក្នុងដី, ត្រងទឹកភ្លៀង, ងូតទឹកភ្លៀង ។

## អំពីនាឡិកា

នាម.– នាឡិកាយោល, នាឡិការោទ៍, នាឡិកាដក់, ផ្ទះនាឡិកា គ្រឿងនាឡិកា, ខ្សែឡាន់ កូនសោ, ប៉ោល, ទ្រនិច, លេខ កញ្ចក់, វ៉ៃ ។

គុណ.– ទៀង, យឺត, លឿន, គាំង, ខូច, ដាច់ឡាន, ថ្មី, ចាស់,

កិរិយា– មួលនាឡិកា ផ្ទៀងនាឡិកា ឬ ម៉ោង បង្វិលទ្រនិច មើលម៉ោង នាឡិកាដើរ នាឡិកាឈប់ (ងាប់)

## សរសេរតាមសូត្រ

ទឹកភ្លៀងកើតមកអំពីពពក ឯពពកកើតឡើងអំពីចំហាយទឹកនៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ប្រមូលផ្ដុំគ្នាឡើងហើយអណ្ដែតទៅឰដ៏អាកាស កាលណាពពកនោះរសាត់ទៅប្រទះនឹងខ្យល់ត្រជាក់ខ្លាំងក៏កកទៅជាទឹកហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសំរាប់ចិញ្ចឹមរុក្ខជាតិទាំងឡាយ ឬផ្ដុំគ្នាកើតបានជាដើមទឹកមួយចំណែកទៀតហូរធ្លាក់

ទៅក្នុងថ្លុក ត្រពាំង, បឹង, ស្ទឹង, ទន្លេ, សមុទ្រ ។ កាលមានភ្លៀងច្រើន តែងមានព្យុះ ផ្គរ (ផ្លេកបន្ទោរ ហើយនឹងរន្ទះផង ។

(ភ្លៀងគេសរសេរបានពីរយ៉ាង „ភ្លៀង ឬ ផ្លៀង" ។

ចូលអ្នកអធិប្បាយអំពីថ្ងៃមួយដែលមានភ្លៀងមួយមេយ៉ាងធំ ។ អ្នកបានឃើញដូចម្ដេចខ្លះ នៅវេលាមុនភ្លៀង វេលាកំពុងភ្លៀង វេលាក្រោយភ្លៀង? យោបល់របស់អ្នក?

អាទិត្យទី ៤ – (សូមសាបស្រៀនពីដើមឡើងវិញ) ។

---

# កុមារដ្ឋាន

## រៀនពាក្យនិងភាសា

### អាទិត្យទី ១ – អំពីភូមិ

នាម – ភូមិ, ក្រុង, ផ្លូវថ្លា, ផ្ទះ, សាលារៀន, សាលាឃុំ, ទន្លេ, ព្រែក, បឹង, របង, ទ្រុងជ្រូក, ក្រោលគោក្របី, ដើមឈើ, ដំណាំ, ចេក ត្របែក, ក្រូច, ម្នាស់, ខ្នុរ ស្វាយ, ដូង, ស្លា, ត្នោត, អំពិល. កន្ទួត, សណ្ដាន់, ក្រសាំង, ខ្វិត, វាលស្រែចំការ,

គុណនាម – ឆ្ងាយ, ជិត, ធំ, ទូលាយ, ខ្ពស់, ទាប, ស្អាត, កខ្វក់, ច្រើន, តិច, ស្អុយ, ឆ្អេះ, ឆ្អាប, ។

កិរិយា — ដើរកាត់ទៅភូមិ, ចេញពីភូមិ, ចូលក្នុងក្រុងធំ, សង់ផ្ទះ, ដាំបេក, បោសសំអាតភូមិ, កាប់ឈើ, ធ្វើក្រោលក្របី, រុះរើទ្រុងជ្រូក, ចាក់ដីពេញថ្លុក, បុកពង្រាបដីភូមិ

ភាសា — ភូមិអ្នកឈ្មោះភូមិអ្វី? ភូមិនោះនៅខាងណាទីក្រុង? ឆ្ងាយ ឬជិត? ភូមិនោះធំឬតូច? បង្អៀតឬទូលាយ? នៅភូមិនោះមានផ្ទះច្រើន ឬតិច? ផ្ទះសង់ខ្ពស់ឬទាប? ដំបូលប្រក់អ្វី? ផ្ទះអ្នកនៅឆ្ងាយឬជិតសាលាឃុំ? នៅភូមិអ្នកមានសាលារៀនឬទេ? មានដើមឈើនិងដំណាំអ្វីខ្លះនៅក្នុងភូមិអ្នក?

## អាទិត្យទី ២ អំពីវត្ត

នាម — ទីធ្លា កំពែង របង ខ្លោងទ្វារ ទន្ទ ផ្លូវថ្លា ដើមឈើ ព្រះវិហារ កុដិ សាលា ព្រះចេតិយ កំពូល រោងទូកង ខ្ទមអ្នកតា ពនទេវតា អាស្រម ផ្ទះដូនជី ក្បាច់រចនា ដើមផ្កា ព្រះពុទ្ធរូប លោកសង្ឃ ឧបាសក ទាយក ៗ

គុណនាម — ធំ ទូលាយ ស្អាត ល្អ រលើប ខ្ពស់ ទាប រាបស្មើ ស្រួច រុងរឿង ចុំចើង រន្ទាលប្រាលភ្លៅ ឆ្ងាយ ជិត

ត្រហាយ ក្រអូប ឈ្ងុយឈ្ងប់ ទ្រហឹងអឹងកង ក្ទឹក្រោងក្រាត ស្ងាត់ឈឹង ៗ

ភាសា -

សុំគ្រូតែងពាក្យចោទសួរសិស្សតាមរបៀបដែលយើងបានធ្វើពីអាទិត្យទី ១ ផងចុះ ៗ

## អាទិត្យទី ៣ និងទី ៤= អំពីក្រុង

នាម= ផ្សារ ផ្លូវថ្នល់ ទន្លេ ព្រែក ស្ពាន ថុក ត្រពាំង ផ្ទះផ្សារ ផ្ទះលក់ទំនិញ គេហស្ថាន វត្តលោក វាំង សាលារៀន រោងមាស៊ីនរោងជាងទង ជាងដែក ជាងឈើ សាលារចនា ចង្កៀងគោមអគ្គិសនី យានជំនិះផ្សេង ៗ ជនានុជន ប្រដាប់ស្លៀកពាក់ ប្រដាប់ប្រើប្រាស់ ៗ

គុណនាម= រុងរឿង ថ្កុំថ្កើង ល្អ អាក្រក់ ស្អាត កខ្វក់ ធំទូលាយ ខ្ពស់ ស្រឡះ សម្បើម មាំ ស្រួល វែង សុខក្សេមក្សាន្ត ជិត ឆ្ងាយ ក្រហេងក្រហូង រាបស្មើ ច្រើនពោរពាស ខ្វាតខ្វែង ឈ្ងួវឆ ទ្រហឹងអឹងកង ចង្អៀតគាន់គាប់ រំពងខ្ទរខ្ទា ក្រឹកក្រេង ៗ

កិរិយា= រៀបចំទីក្រុង ចាក់ដី លុបថកត្រពាំង យកខ្សាច់

កិនស្រូវ ធ្វើស្ពាន សង់ផ្ទះ ដើរលេងផ្សារ លក់ទំនិញ ទៅទិញសំពត់ ជិះរទេះ ឆ្លងកាត់ព្រៃ ចូលក្នុងផ្សារ ដើរត្រួតត្រា ឈរយាមល្បាត បោសថ្នល់ កើបសំរាម បង្ហូរទឹកស្អុយ

អាទិត្យទី ១ – មេឃុំនៅភូមិយើង

(សៀវភៅវិជ្ជាខេមរភាសា បរិច្ឆេទ- ទំព័រ ៨២)

អាទិត្យទី ២ – អ្នកយាមល្បាតនៅក្នុងភូមិ

(សៀវភៅដដែល ទំព័រ ៨៤)

អាទិត្យទី ៣ និងទី ៤ –

ព្រះវិហារព្រះកែវមរកតនៅក្រុងភ្នំពេញ

(សៀវភៅដដែលទំព័រ ១០៩)

---

## បរិច្ឆេទផល្គុន

**បង្រៀនពាក្យនិងភាសា**

អាទិត្យទី ១ – អំពីពេលវេលា

នាម = ថ្ងៃ យប់ អាទិត្យ ខែ ឆ្នាំ មួយរំពេច មួយស្របក់ ម៉ោង នាទី (មីនុត) វិនាទី (សឺកុង)

គុណនាម – ភ្លឺ ងងឹត យូរ ឆាប់ ឆ្នាំចាស់ ឆ្នាំថ្មី ខែមុន ខែក្រោយ ដើមខែ ចុងខែ កណ្ដាលខែ ៗ

កិរិយា = ខាតពេលវេលា កត់ថ្ងៃខែឆ្នាំ មើលម៉ោង ថ្ងៃរះ ថ្ងៃលិច ថ្ងៃចាំង ៗ

ភាសា = ដែលគេហៅថាពេលវេលានោះគឺអ្វី? ក្នុងមួយឆ្នាំមានប៉ុន្មានខែ? គឺខែអ្វីខ្លះ? ឯឆ្នាំគឺឆ្នាំអ្វីខ្លះ? ក្នុង ១ អាទិត្យមានប៉ុន្មានថ្ងៃ? គឺថ្ងៃអ្វីខ្លះ? ក្នុង១ ខែមានប៉ុន្មានថ្ងៃ? ក្នុង ១ ថ្ងៃ ១ យប់មានប៉ុន្មានម៉ោង?

## អាទិត្យទី ២ – អំពីខ្យល់

នាម = ខ្យល់ ខ្យល់រំភើយ ខ្យល់ដំនោរ ខ្យល់ព្យុះ ព្យុះសង្ឃ្រា ខ្យល់កំបុតត្បូង (ខ្យល់គួច) ខ្យល់ពីងដើង ៗ

គុណនាម = រហើយត្រសៀក ត្រជាក់ រងា តិច ខ្លាំង វក់វី ៗ

កិរិយា = ខ្យល់បក់តិច ៗ ខ្យល់បក់ខ្លាំង ខ្យល់គួចធូលី បង្ហើរខ្លែង បើកក្ដោង ៗ

## អាទិត្យទី ៣ – អំពីភ្លៀង-ឥន្ទធនូ

នាម.– ភ្លៀង, ផ្គរ, រន្ទះ, ផ្លេកបន្ទោរ, ឥន្ទធនូ, សន្សើម, គ្រាប់ភ្លៀង, ទឹកភ្លៀង ។

គុណនាម.– ច្រើន, តិច, ស្រិចៗ, ប្រុយៗ, រលឹម, ទទឹកជោក, សើម ។

កិរិយា.– រាំងភ្លៀង, ភ្លៀងស្រក់តក់ៗ, ទឹកភ្លៀងដក់, ទឹកភ្លៀងជ្រាបទៅក្នុងដី, ត្រងទឹកភ្លៀង, ងូតទឹកភ្លៀង

## អាទិត្យទី ៤.– អំពីនាឡិកា

នាម.– នាឡិកា, ឬនាលិកា, នាឡិកាយោល, នាឡិកាពេទ នាឡិកាដក់, ផ្ទះនាឡិកា, គ្រឿងនាឡិកា, ខ្ចៅឡាន, កូនសោ ប៉ោល, ទ្រនិច, លេខ, កញ្ចក់, យ៉ៃ ។

គុណនាម.– ទៀង, យឺត, លឿន, តាំង, ខូច, ដាច់ឡាន, ថ្មី, ចាស់ ។

កិរិយា.– មួលនាលិកា, ផ្ទៀងនាឡិកាឬម៉ោង, បង្វិលទ្រនិច មើលម៉ោង នាឡិកាដើរ, នាឡិកាឈប់ (ច្រើនថានាឡិកាងាប់) ។

# បង្រៀនមើល

## អាទិត្យទី ១.- អំពីពេលតាមរបៀបខ្មែរ

(សៀវភៅវត្តស្វាធ្យាយន៍បរិ. ទំព័រ ១០៨)

## អាទិត្យទី ២.- អំពីខ្យល់បក់មកពីទិសខាងជើង

សៀវភៅខេមរភាសា បុរិ. ទំព័រ ៦៤)

## អាទិត្យទី ៣. អំពីភ្លៀង

ទឹកភ្លៀងបង្កើតមកពីពពក ឯពពកកើតឡើងអំពីចំហាយទឹក នៅវេលាដែលត្រូវកំដៅព្រះអាទិត្យ ផ្តុំគ្នាឡើងហើយ អណ្តែតទៅលើអាកាស កាលណាពពកនោះរសាត់ទៅប៉ះខ្យល់ត្រជាក់ខ្លាំងកកកទៅជាទឹក ហើយធ្លាក់មកជាទឹកភ្លៀង ទឹកភ្លៀងជ្រាបទៅក្នុងដីសំរាប់ចិញ្ចឹមរុក្ខជាតិទាំងឡាយ ឬផ្តុំគ្នាកើតបានជាដង្ហើមទឹក ៗ មួយចំណែកទៀតហូរធ្លាក់ទៅក្នុងថ្លុកត្រពាំងបឹង ស្ទឹង ទន្លេ សមុទ្រ ៗ កាលណាមានភ្លៀងច្រើនមានព្យុះផ្គរ ផ្លេកបន្ទោរហើយនឹងរន្ទះធំ ៗ

ពាក្យពិបាក – ផ្តុំ, អណ្តែត, រសាត់, រុក្ខជាតិ, ព្យុះផ្គរ, ផ្លេកបន្ទោរ ៗ ភ្លៀងសរសេរបានពីរយ៉ាង ភ្លៀងឬផ្លៀង ៗ

មជ្ឈិមដ្ឋាន ទី ១

ឥពន្ធ ១

# លេខចែកចំនួនអនិយមភាគ

ឧបមា: ៤ថ្ងៃ ១៣ម ៤៧មន ៥០ស ចែកនឹង ៨

៤ថ ១៣ម ៤៧មន • ៥០ស

២៤ម × ៤ = ៩៦ម

១០៩ម

២៩

៥

៦០មន × ៥ = ៣០០មន

៣៤៧មន

× ២៧

៣

៦០ស × ៣ = ១៨០ស

២៣០មន

៧០

៦

| ៨
| ១៣ម ៤៣មន ២៨ស

គេសំរាយ ៤ ថ្ងៃទៅជាម៉ោងហើយ គេបញ្ចូលលទ្ធផលទៅ ១៣ ម៉ោង បានជា ១០៩ ម៉ោងទើបយកទៅចែកនឹង ៨ ឃើញបាន ១៣ ម៉ោងនៅសល់ ៥ ម៉ោង ។ សេស ៥ ម៉ោងនេះត្រូវសំរាយឲ្យទៅជាមីនុតគឺបានលទ្ធផល ៣០០ មីនុត ។ នេះយកទៅបញ្ចូល ៤៧ មីនុតបាន ៣៤៧ មីនុតទៅចែកនឹង ៨ ឃើញបាន ៤៣ មីនុតនៅសល់ ៣ មីនុត ។

គេសំរាយ ៣ មីនុតឲ្យទៅជាសឹកុង ឃើញលទ្ធផល ១៨០ សឹកុង

ទើបយកលទ្ធផលនេះទៅបញ្ចូលនឹង ៥០ សីកុង ឃើញបាន ៦៣០ សី-កុង នៅសល់ ៦ សីកុង ។

មេរៀន.— ដើម្បីនឹងចែកលេខចំនួនអនិយមភាគ នឹងចំនួនអ្វីមួយ គេត្រូវចែកលេខដែលនៅខាងឆ្វេងដៃ គឺ លេខដែលធំជាងគេនឹងចំនួននោះ បើចែកទៅហើយមិនដាច់ គឺនៅសល់ គេសំពយពេលដែលសល់នោះទៅជាពេលដែលនៅបន្ទាប់ឆ្វេងដៃរួចគេបូក ទើបឃើញលទ្ធផលប៉ុន្មានយកទៅចែកតាមលំដាប់ត ៗ ទៅ ។

វិធីហាត់គិតគិតធ្វើលេខ.— អ្នកជិះទោចក្រយាន ១ ជិះបានក្នុងមួយម៉ោង ១២ គីឡូម៉ែត្រ តើចម្ងាយ ៣៦ គ. ម. គេជិះប៉ុន្មានម៉ោង ? ។ល។ ។

វិធីហាត់សរសេរ.— កប៉ាល់សមុទ្រមួយបើកបានចម្ងាយ ២.៤០០ គ. ម. ក្នុង ៨៥ ម៉ោង តើក្នុង ១០០ គ. ម. កប៉ាល់នោះបើកប៉ុន្មានម៉ោង ? ។ល។

មេរៀនទី ២.— លេខចែកនឹង ០,៥០—០, ២៥ ដើម្បីនឹងចែកចំនួនគូនឹង ០,៥០ គេត្រូវគុណចំនួននោះនឹង ២ ឧបមា: ទំមួយថ្លៃ ០រ ៥០ តើប្រាក់ ៧រ, ទិញបានទំប៉ុន្មាន ? គឺយក ៧រ គុណនឹង ២ ឃើញបានទំ

១៤ ។ ដើម្បីនឹងចែកចំនួនអ្វីនឹង ០,២៥ គេត្រូវគុណចំនួននោះនឹង ៤ ។

ឧបមា: ស្លាបប៉ាកកាមួយថ្លៃ ០៛២៥ តើប្រាក់ ៨៛, ទិញបានស្លាបប៉ាកកាប៉ុន្មាន ?

គឺ: យក ៨ គុណនឹង ៤ ឃើញស្លាបប៉ាកកា ៣២ ។

## វិធីហាត់គិតគិតធ្វើលេខ

ចែកនឹង ០,៥០,: ប្រាក់ ៣៛; ៧៛; ១២៛; ៨៛ ៥០; ១៤៛ ៥០ ទិញបានបន្ទាត់ប៉ុន្មាន បើបន្ទាត់មួយថ្លៃ ០៛៥០ ។

ចែកនឹង ០, ២៥: ដបទឹកខ្មៅមួយចំណុះ ០$^{លី}$២៥ តើបានទឹកខ្មៅប៉ុន្មានដបបើគេយកទៅចាក់ ៧$^{លី}$; ៣$^{លី}$,៥; ៤$^{លី}$,២៥; ២៥$^{លី}$ ?

## រង្វាស់រង្វាល់

សូមសាបរៀនតាំងពីដើមឆ្នាំមកវិញ ហើយសាកសួរវិធីមុនៗ នឹងដាក់ចំណោទឲ្យសិស្សធ្វើឲ្យបានច្រើន ។

## អាគិតដ្ឋាន

### នព្វន្ត

ទី ១.- សាបស្រៀនអំពីលេខបូកទាំងពីរយ៉ាងឡើងវិញ ។

១- **វិធីហាត់គិតតិតធ្វើលេខ.**- លេខបូកជាអ្វី ? (ជាវិធីមួយសំរាប់ប្រមូលចំនួនអ្វីដែលដូចគ្នាមកធ្វើជាចំនួនមួយ) ។ ដើម្បីនឹងសរសេរហើយនឹងបូកលេខនោះ គេត្រូវសំគាល់ដូចម្តេច? គេត្រូវសំគាល់ខ្ទង់គឺ ចំនួនរាយក្រោមចំនួនរាយ ចំនួនដប់ក្រោមចំនួនដប់ ។ល។

២- **វិធីហាត់សរសេរ.**- ចូរធ្វើលេខបូកដូចមានដាក់នៅខាងក្រោមនេះ

៦៦១៣រ + ២៣រ + ៥៣៦រ = ... ២២៧ម + ៧៩២ម ៥ = ......

២៥៦រ,៧ + ៥៨រ,៥៦ + ៩៦៣រ,៥= ... ២៩៩ម៧២ + ៩៦២ម= ។

៣- **បំណោទ.**- ទូកប៉ុកចាយមួយផ្ទុកឥដ្ឋបីថ្ងៃក្នុងថ្ងៃទី១ ផ្ទុកបាន ៦៨៥ ដុំ ថ្ងៃទី ២ បាន ៤៦៩ ដុំ ថ្ងៃទី ៣ បានស្មើនឹង ថ្ងៃទី ១ នឹងទី ២ រួមគ្នា តើក្នុង ៣ ថ្ងៃទូកនោះផ្ទុកបានឥដ្ឋប៉ុន្មានដុំ ? ។

៤.- អ្នកស្រែចំការម្នាក់ បាន ទិញ ស្រូវ ២៧ ហ,ល. ថ្លៃ ១៩៨៨រ,៧៥ រួច ៣៧ ហ.ល ៥០ ថ្លៃ ២.៤៧៥រ,៥០ ។ តើអ្នក-

ស្រែនោះទិញទាំងអស់បានប៉ុន្មានហិកតូលីត្រ ? ហើយត្រូវលក់ស្រូវនោះទៅវិញថ្លៃប៉ុន្មានឲ្យបានចំណេញ ១២៩០៛,៧៥ ? ។

ទី ២.– សាបព្រៀនអំពីលេខសងឡើងវិញ ។

១– វិធីហាត់គិតគិតធ្វើលេខ.– លេខសងជាអ្វី ? (ជាវិធីមួយសំរាប់ដកបុកាត់ចំនួនតូចមួយពីចំនួនធំមួយ) ។ គេធ្វើលេខសងដូចម្តេច ? (គេសរសេរចំនួនតូចដាក់ក្រោមចំនួនធំឲ្យត្រង់ជួរ គឺខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់ដប់ក្រោមខ្ទង់ដប់) ។ល។

២– វិធីហាត់សរសេរ.– ចូរធ្វើលេខសងខាងក្រោមនេះបានធ្វើបញ្ជាក់ឲ្យដឹងខុសត្រូវផង ។

២៨៧៧ម – ៤៣៩ម= .... ។ ១៥៣២ម – ៧៥៣ម ២៥= .... ។

៩៩២៛,៨ – ៥៣៦៛= .... ។ ៧៩២៣៛,៦៥ – ២៨៤៛,៧៨= ....។

៣– បំណោទ.– ឈ្មួញឈើម្នាក់មានប្រាក់ ២២៥៣៨៛,៥០ ហើយគេទិញឈើមួយកន្លែងអស់ ៧៦៣៤៛,២៥ មួយកន្លែងទៀតអស់ ៨២៨៦៛,៦០ តើឈ្មួញនោះនៅសល់ប្រាក់ប៉ុន្មានទៀត ? ។

៤– ឈ្មួញម្នាក់ចេញថ្លៃឲ្យកូនជាង ៣ នាក់ចំនួនប្រាក់ ៧០០៛ ។. កូនជាងទីមួយបាន ២៥៧៛,៧៥ ជាងទី ២ បានតិចជាងទីមួយ ៣៩៛,៥០ ហើយជាងទី ៣ ត្រូវបានប្រាក់ដែលនៅសល់ តើម្នាក់ៗត្រូវបានប៉ុន្មាន ។

ទី ៣.– សាបស្រៀនអំពីលេខគុណចំនួនដុំនឹងចំនួនទសភាគលេខគុណនឹង ១០ ។ ១០០ ។ ១.០០០ ។ ហើយនឹងរបៀបធ្វើបញ្ជាក់ឲ្យឃើញខុសត្រូវនោះឡើងវិញផង ។

**វិធីហាត់គិតគិតធ្វើលេខ.–** លេខគុណជាអ្វី? (ជាវិធីមួយសំរាប់បង្កើនចំនួនមួយឲ្យបំរើនធំឡើងមានកំណត់) ។ លេខតំណាងគឺអ្វី? មេគុណគឺអ្វី?

មួកមួយថ្លៃ ៥រ បើមួក ៥ ។ ១០ ។ ១០០ ។ ១.០០០ ។ ថ្លៃប៉ុន្មាន? ។ គេធ្វើដូចម្ដេចដើម្បីនឹងគុណចំនួនគត់នឹង ១០ ។ ១០០ ។ ១០០០ ។ បើលេខតំណាងជាចំនួនមានបែងភាគរយគេធ្វើដូចម្ដេច? ។ល។

២.– បំណាច.– ចិនម្នាក់ទិញមួក ៥២ ហើយលក់ទៅវិញថ្លៃ ១៨០រ មួយ រួចចិននោះគិតឃើញចាំងអស់ ៦៣០រ តើថ្លៃដើមមួកនោះចាំងអស់ប៉ុន្មាន? ។

៣.– ជាងឈើម្នាក់រកបានក្នុងមួយថ្ងៃ ១៦រ៥០ វាធ្វើការរាល់ថ្ងៃ ១ ឆ្នាំលើកតែ ៥២ ថ្ងៃអាទិត្យ ហើយនឹងថ្ងៃបុណ្យ ៦ ថ្ងៃចេញ ។ ថ្លៃឈ្នួលផ្ទះ ៧២០រ ហើយសន្សំទុកបាន ៦០០រ តើជាងនោះនៅសល់ប្រាក់ប៉ុន្មាននឹងចាយវាយក្នុងគ្រួសារ? ។

ទី ៤.– សាបង្រៀនអំពីលេខចែក ដែលបានបង្រៀនក្នុងឆ្នាំនេះឡើងវិញ ។

១– **វិធីហាត់មាត់ទទេ.–** សូមមើលវិធីនេះក្នុងកិច្ចសិក្សាបឋមវិជ្ជាតាំងពីខែសេបតមប្រ៍រហូតមកដល់ខែមេ៉នេះ ។

២– **បំណេញ.–** ឈ្មួញម្នាក់ទិញសំពត់ហូល ៨ ហើយលក់ទៅវិញតាំងអស់បានប្រាក់ ៦៤០ រៀល គេគិតទៅឃើញបានបំណេញ ១៥០ រៀល តើថ្លៃដើមសំពត់នោះ ១ ប៉ុន្មាន ? ។

## វង្វាស់ វង្វាល់

ទី១.– សាបង្រៀនអំពីវង្វាស់ប្រវែងឡើងវិញ ។

១– **វិធីហាត់គិតតិតធ្វើលេខ** ខ្នាតដើមនៃវិធីវាស់ប្រវែងនោះគឺអ្វី ? ម៉ែត្រគេធ្វើអំពីអ្វី ? មានបែបយ៉ាងណាខ្លះ ? វង្វាស់តូចជាងម៉ែត្រនោះគឺអ្វីខ្លះ ? ខ្នាតធំជាងម៉ែត្រនោះគឺអ្វីខ្លះ ?

២–**វិធីហាត់សរសេរ** ឲ្យសរសេរជាម៉ែត្រចំនួនខាងក្រោយនេះ

១៧ម ។ ៨ហ.ម ។ ៣២ដ ក ។ ២៥ស.ម ។ ៧ហ.ម ។ ៨.០០០ម.ម

៨៥៣ស.ម ។ ៤ដ.ម២៥ស.ម ។

៣ បំណោទ៖ អ្នកវេញខ្សែម្នាក់ វេញខ្សែនៅថ្ងៃច័ន្ទបាន ៣៥ម៉ែត្រ ថ្ងៃអង្គារបាន៨ម៉ែត្រ លើសថ្ងៃច័ន្ទ ហើយថ្ងៃពុធបាន ៩ ម៉ែត្រលើសថ្ងៃអង្គារទៀត ។ តើក្នុង៣ថ្ងៃនោះគេវេញខ្សែបានប៉ុន្មានម៉ែត្រ ?

ឈ្មួញម្នាក់ជំពាក់ទំនិញគេ ៩៦៦រ៥០ វាសងជាប្រាក់ ១២៥រ៥០ ហើយនៅសល់ប៉ុន្មានទៀតជាសំពត់គិតថ្លៃ១៤រក្នុង១ម៉ែត្រ ។ តើឈ្មួញនោះត្រូវសងសំពត់ទៅគេប៉ុន្មានម៉ែត្រ ? ។

ទី២ — សាបង្រៀនអំពីវង្វាល់ចំណុះ

វិធីហាត់គិតផ្ទៀលេខ ចោទសួរពីការណាអំពីវាល់ ទឹងផ្លាស់វង្វាល់ ធំទៅតូចរួចតូចមកធំវិញ ។

២ បំណោទ៖ គេចាក់ទឹកទៅក្នុងថាំងធំមួយ ។ លើកដំបូង២ហ.ល កន្ទះ មួយលើកបន្ទាប់៤ដ.ក.ល កន្ទះ ហើយលើកក្រោយបំផុត២៤លីត្រ គេសួរថាចុះគេចាក់ទឹកទៅក្នុងថាំងនោះទាំងអស់ប៉ុន្មាន ? ។

ទី៣ទី៤ — ១.— សាបង្រៀនអំពីវង្វាល់ចំណុះដែលមានរូបជាក់ស្តែងគឺវង្វាល់ដែលមានធ្វើទុកការវាល់ផ្ទាល់ទឹងដែបាន ។

២.— សាបង្រៀនអំពីរូបិយវត្ថុ ដែលបានបង្រៀនរួចមកហើយ ។

បំណោទ ៈ ១– ចិនម្នាក់ទិញស្រា ១៥ឌុស៊ិន ថ្លៃ ១ ឌុស៊ិន ៦២រ៥០ ហើយចិននោះលក់ពាយទៅវិញ ១០រ៣០ ក្នុង១លីត្រ តើចិននោះចំណេញបានប៉ុន្មាន បើក្នុង១ឌុស៊ិនមានចំណុះ ២ដ.ក.ល កន្លះ ?

២.– មានបងប្អូន ៣ នាក់ទៅស៊ីឈ្នួលឲ្យគេក្នុង ១ ថ្ងៃបងបង្អស់បានឈ្នួល ៨រ៥០ ប្អូនបន្ទាប់បាន ៦រ៤០ ប្អូនពៅបាន ២រ៧០ គេសួរថាចុះទាំងអស់គ្នាបានសល់ប្រាក់ប៉ុន្មានរៀលមកផ្ទះ បើក្នុងកំឡុងធ្វើការនោះ ១អាទិត្យហើយចាយទាំងអស់គ្នាអស់៧០រៀល ? ។

## ធរណីមាណសាស្ត្រ

អាទិត្យទី ១.– សារៀនអំពីផ្ទៃ ៤ ជ្រុងស្មើ

របៀបបង្រៀន.– ចោទសួរអំពីទីយ៉ាងផ្ទៃ ៤ ជ្រុងស្មើ ៗ ទីងរកផ្ទៃ ៤ ជ្រុងស្មើត្រូវធ្វើដូចម្តេចខ្លះ ៗ ទីងគិតរកពាក់កណ្តាលបរិវេណ ទីងរកបរិវេណទាំងមូល ៗ

ការហាត់គិតដោយបញ្ញា ឬ នៅលើក្តារខៀន? សុំឲ្យធ្វើឲ្យបានច្រើន ស្រែមួយរាង ៤ ជ្រុងស្មើ ១ជ្រុងប្រវែង ៧ ម៉ែត្រ តើពាក់កណ្តាលបរិវេណស្រែនោះទំហំប៉ុន្មាន ៗ បរិវេណទាំងមូលទំហំប៉ុន្មាន ៗ ស្រែនោះទំហំប៉ុន្មានម៉ែត្រក្រឡា ៗ

អ្នកចំការម្នាក់ទិញដី ១ក្បាលការ៉េ ៤ជ្រុងស្មើ ១ជ្រុងប្រវែង ៣៦ ម៉ែត្រ ថ្លៃក្នុងមួយម៉ែត្រក្រឡា ៨រៀល៩០ តើអ្នកនោះចំណាយអស់ប៉ុន្មាន ?

ការហាត់សរសេរ.— គេទិញដីការ៉េ ៤ជ្រុងស្មើ ១កន្លែង ១ជ្រុងប្រវែង៥៨ម៉ែត្រ៥០ ថ្លៃក្នុង១ម៉ែត្រក្រឡា៥៩ៀ ៣៥ ហើយគេធ្វើរបងព័ទ្ធជុំវិញគិតទៅក្នុង ១ ម៉ែត្រអស់ ២៣ៀ ២៥ តើអ្នកចំណាយទាំងអស់ ? ប៉ុន្មាន ?

អាទិត្យទី ២.— សារៀនអំពីផ្ទៃ ៤ ជ្រុងទ្រវែង

របៀបបង្រៀន:- ធ្វើដូចកាលបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ចោទ-សួរឲ្យរកន័យ ពាក់កណ្ដាលបរិវេណ បរិវេណទាំងមូល ផ្ទៃក្រឡា ៗ កាលណាគេដឹងបរិវេណហើយនិងបណ្ដោយ គេធ្វើដូចម្ដេចនឹងឲ្យឃើញទទឹង ? បើដឹងបរិវេណនិងទទឹង ត្រូវធ្វើដូចម្ដេចឲ្យឃើញបណ្ដោយ ? បើចង់ឲ្យឃើញបណ្ដោយ ហើយនឹងផ្ទៃនិងទទឹង តើត្រូវធ្វើដូចម្ដេច ? ធ្វើដូចម្ដេចឲ្យឃើញទទឹង បើដឹងផ្ទៃនិងបណ្ដោយ ? ល ៗ

ការហាត់ដោយបញ្ញា និង នៅលើក្ដារខ្នួន: សុំជ្រើសរើសកិច្ចការឲ្យហាត់គិតគូរដូចរបៀបបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ។

ការហាត់សរសេរ.— សុំលោកគ្រូជ្រើសរើសកិច្ចការដាក់ឲ្យធ្វើផងចុះ ។

អាទិត្យទី៣.— សារៀនអំពីត្រីកោណ

របៀបបង្រៀន.— ចោទសួរដូចកាលបង្រៀនផ្ទៃ ៤ ជ្រុងស្មើ ផ្ទៃ ៤ ជ្រុងទ្រវែង ឲ្យរកន័យ រកបរិវេណ ។

ត្រីកោណមានប៉ុន្មានយ៉ាង ។ អ្វីខ្លះ ។ ទឹងរកបរិវេណត្រីកោណស្មើជ្រុងតែ ២ ធ្វើដូចម្តេចខ្លះ ។ ត្រីកោណស្មើជ្រុង ។ ត្រីកោណឥតស្មើជ្រុង ។ ត្រីកោណស្មើជ្រុងទាំង ៣ ។ ធ្វើដូចម្តេចទឹងរកក្រឡាផ្ទៃត្រីកោណ ទឹងរកបាត ។ ទឹងរកកំពស់ ។

ការហាត់គិតដោយបញ្ញាឬលើក្តារខ្មៀន: សុំធ្វើដូចមុនៗ ។

ការហាត់សរសេរ: សុំលោកគ្រូជ្រើសរើសរកកិច្ចការដាក់ឲ្យធ្វើផងចុះ ។

អាទិត្យទី៤: សារៀនអំពីវណ្ណមណ្ឌលទីនផ្ទៃរង្វង់ ។

របៀបបង្រៀន: សុំសាកសួរដូចពីកាលជាន់មុនៗ ឲ្យរកន័យ

ខាតវណ្ណមណ្ឌល (បន្ទាត់ពុះទឹកកាំ) របៀបគេប្រើវណ្ណមណ្ឌល គេបន្ទាត់ពុះ គេកាំ ៗ គេនយ័ផ្ទៃធ្នូ ការគិតគូរកផ្ទៃធ្នូ គេកាំ ៗ

---

## កុមារដ្ឋាន

### គព្វគ្ដ

តាមកំណត់បែកវិជ្ជាក្នុងខែនេះជាខែចុងឆ្នាំសិក្សា គ្រូសាបម្រៀនមេរៀនផ្សេង ៗ ដែលបានបង្រៀនតាំងពីដើមឆ្នាំមក ឲ្យសិស្សហាត់ធ្វើលេខធ្វើចំណោទផ្សេង ៗ តាមជំរិះរបស់សិស្ស ៗ

សូមមើលតាមរបៀបរៀបចំជាតំរុក្នុងទស្សនាវដ្ដីខែមុន ហើយសូមតែងការហាត់ឲ្យសព្វគ្រប់តាមចំណេះរបស់សិស្ស ៗ

### រង្វាស់ - រង្វាល់

សូមសាបម្រៀនមេរៀនផ្សេងៗ ដែលសិស្សបានរៀនតាំងពីដើមឆ្នាំមក ៗ ឲ្យសិស្សហាត់ធ្វើលេខនឹងធ្វើចំណោទឲ្យបានច្រើនផង ៗ

## បរិច្ឆណាដ្ឋាន

### នព្វន្ត

មេរៀនទី ១.– សាបញ្ជាក់អំពីលេខបូកចំនួនដុំនឹងចំនួនបែងភាគ ដែលបានរៀនរួចមកហើយ ។

របៀបបង្រៀន   ចោទជាចំណោទបែបដូចជា ៖

ម្តាយខ្ញុំលក់អង្ករមួយគៅបានប្រាក់ ៤២៛, លក់មាន់ ២ បានប្រាក់ ៣៤៛, លក់កូនជ្រូក១ បានប្រាក់ ៧៣៛ ។ តើគាត់ត្រូវបានប្រាក់ទាំងអស់-ប៉ុន្មាន ? ។

របៀបពន្យល់ដោយចោទសួរ.– ក្នុងចំណោទនេះគេសួររកអ្វី? គេត្រូវធ្វើដូចម្តេច ? ចូរធ្វើលេខបូកនោះទៅមើល ។

កាលណាសិស្សធ្វើលេខបូកនោះត្រឹមត្រូវហើយ គ្រូចោទចំណោទមួយទៀតដែលមានលេខបូកចំនួនទសភាគ ។ បើសិស្សចេះសព្វគ្រប់-ហើយត្រូវដាក់ការហាត់សរសេរឲ្យធ្វើនៅក្នុងសៀវភៅ បើពិនិត្យទៅឃើញថាសិស្សពុំទាន់យល់ច្បាស់ត្រង់កន្លែងណា ត្រូវសាពន្យល់កន្លែងនោះឲ្យសិស្សយល់ច្បាស់ឡើង ។

## ការហាត់សរសេរនៅក្នុងសៀវភៅ.- ចំណោទ

១- ស្រីម្នាក់ទៅផ្សារទិញអង្ករ ២ តៅ អស់ប្រាក់ ៨៣៛, ទិញសំពត់ ៥ម អស់ ១០៧៛ ហើយទិញម្ហូបអាហារអស់ ២៥៛ ។ តើស្រីនោះចាយអស់ប្រាក់ប៉ុន្មាន? ។

២- អ្នកចំការម្នាក់ទៅផ្សារលក់ផ្លែឈើបានប្រាក់ ២៣៛,៥៣ លក់បន្លែបានប្រាក់ ១៧៛,៤៦ ។ តើអ្នកនោះលក់បានប្រាក់ទាំងអស់ប៉ុន្មាន? ។

មេរៀនទី ២.- សាបញ្ជាក់អំពីលេខបង់ចំនួនដុំ នឹងចំនួនទសភាគដែលបានរៀនរួចមកហើយ ។

សូមមើលរបៀបតាមខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

មេរៀនទី ៣.- សាបញ្ជាក់អំពីលេខគុណចំនួនដុំនឹងចំនួនទសភាគមេគុណមានលេខតែមួយតួ ។

មេរៀនទី ៤.- សាបញ្ជាក់អំពីលេខចែកចំនួនដុំ-ចំនួនទសភាគនឹងលេខហារ មានលេខតែមួយតួ ។

សូមតែងការហាត់ឲ្យសព្វគ្រប់តាមរបៀបខាងលើនេះផង ។

# រង្វាស់ រង្វាល់

មេរៀនទី ១.– សាបញ្ជាក់អំពីរង្វាស់ (ម៉ែត្រ)

រង្វាស់ដែលធំជាងម៉ែត្រ-តូចជាងម៉ែត្រ-និងរង្វាស់ដែលមានជាប្រធាន ។

មេរៀនទី ២.– សាបញ្ជាក់អំពីរង្វាល់ (លីត្រ)

រង្វាស់ដែលធំ និង តូចជាងលីត្រ-រង្វាស់ដែលមានជាប្រធាន ។

មេរៀនទី ៣.– សាបញ្ជាក់អំពីកូនទម្ងន់ (ក្រាម)

កូនទម្ងន់ដែលតូច និងធំជាងក្រាម-កូនទម្ងន់ដែលមានជាប្រធាន ។

មេរៀនទី ៤.– សាបញ្ជាក់អំពីប្រាក់ដែលចាយនៅប្រទេសឥណ្ឌូចិន ។

ការបំណាំ.– សូមបង្ហឹកសិស្សឲ្យចេះវាស់ - វាល់ - ថ្លឹង - ដូរប្រាក់ - ថែមថយប្រាក់បានស្ទាត់ផង ហើយសូមតែងការហាត់ឲ្យបានសព្វគ្រប់ផង ។

# មជ្ឈិមដ្ឋានទី ១

## វិត្តស្វាធ្យាយន៍

អាទិត្យទី ១.– ប្រៃសណីយ - ទូរលេខ, ទូរសព្ទ មានខ្សែនឹង ទូរសព្ទឥតខ្សែ ។

មេរៀនសង្ខេប.– គេឲ្យដំណឹងកាន់គ្នាទៅវិញទៅមក ដោយ សំបុត្រឬដោយទូរលេខឬទូរសព្ទ ។

ដើម្បីនឹងផ្ញើសំបុត្រ គេត្រូវបិទតែមតាម កំណត់ច្បាប់ ហើយយក សំបុត្រនោះទៅដាក់ក្នុងប្រអប់សំរាប់ទទួលសំបុត្រនៅឯមន្ទីរប្រៃសណីយៗ នៅមន្ទីរនោះភ្នាក់ងារប្រៃសណីយចាត់ផ្ញើសំបុត្រនានាឲ្យអ្នកទទួលដល់ទី-កន្លែងតាមអាស័យដ្ឋាន (ម.ថ. អាស័យ - យ៉ាត់ - ដ្ឋាន : Adresse ដោយរថយន្ត, រថភ្លើង, យន្តហោះឬដោយកប៉ាល់ ។ (សុំគ្រូយក-ស្រោមសំបុត្រមួយមកបង្ហាញសិស្ស ហើយ បង្ហាញ របៀបកាខ្ទង់ នឹង របៀបបិទតែម ).

ទូរលេខជាគ្រឿងមួយបែបសំរាប់ផ្ញើដំណឹងបានយ៉ាងឆាប់ទាន់ចិត្ត ។ គ្រឿងនេះដើរដោយកម្លាំងអគ្គិសនីហើយ ភ្ជាប់ពីកន្លែងមួយទៅកន្លែងមួយ

ដោយខ្សែលួសធ្វើពីលោហធាតុ ។ ដូនណាគេបង្កប់ខ្សែលួសនេះតាមបាតសមុទ្រឬទន្លេក៏មាន ។ ក្នុងការប្រើគ្រឿងនេះគេសន្មតប្រើគំនូសដំនួសព្យញ្ជនៈនានា ។

ឧទាហរណ៍: a: . - ; b: - ... ; c: - . - . ។

ទូរសព្ទមានខ្សែគឺជាគ្រឿងសំរាប់ផ្ញើសព្ទឬសញ្ញាដែលគេសន្មតប្រើតាមលំហអាកាសដោយឥតចាំបាច់ប្រើខ្សែឡើយ ។

អាទិត្យទី ២.- ម៉ាស៊ីនដើរដោយកម្លាំងចំហាយទឹក

ទឹកពុះក្នុងកំសៀវ អាចធ្វើឲ្យគំរបកំសៀវរបើក បាន មក ពីកម្លាំងចំហាយទឹក ។ បើកាលណាគេយកបំពង់ដែកមួយមកដាក់ទឹកពាក់កណ្ដាល ហើយចុកឲ្យជិតរួចយកទៅកំដៅក្នុងមិនយូរប៉ុន្មានទឹកនឹងពុះ បន្ទាប់មកគេនឹងឃើញឆ្នុកនោះខ្ទាតចេញជាពុំខានដោយសារចំហាយទឹកផាក់ ។

គឺកម្លាំងចំហាយទឹកនេះហើយដែលនាំឲ្យម៉ាស៊ីនរថភ្លើង, ម៉ាស៊ីនកិនស្រូវបើកបរបាន ។ តែដើម្បីនឹងឲ្យទឹកពុះមានចំហាយ គេត្រូវដុតធ្យូងឲ្យមានកំដៅខ្លាំង ។ ដូច្នេះសម្រេចទៅគឺភ្លើងធ្យូងនេះ ដែលជាហេតុនាំឲ្យគ្រឿងម៉ាស៊ីនកប៉ាល់ឬរថភ្លើងដើរបាន ។

អាទិត្យទី ៣.- រថយន្តនិងយន្តហោះ

ម៉ាស៊ីនបំពូកនេះមិនដើរដោយកម្លាំងចំហាយទឹកពុះឡើយ គេដឹងថាគ្រោះថ្នាក់នឹងមានជាប្រាកដដល់ជនណាដែលកាន់ចង្កៀងឬចន្លុះដែលកំពុងឆេះមានអណ្តាតចូលទៅក្នុងកន្លែងណាមួយដែលមានចំហាយប្រេងសាំង ព្រោះចំហាយប្រេងសាំងនឹងខ្យល់លាយគ្នា តែកាលណាមកប៉ះអណ្តាតភ្លើងនឹងឆេះហើយផ្ទុះផង ។

អ្នកប្រើចង្កៀងដុតស្រាចាស់ពេកឬខូចក៏មានគ្រោះថ្នាក់ដែរពីព្រោះចំហាយស្រាដុតលាយនឹងខ្យល់តែប៉ះនឹងអណ្តាតភ្លើងក៏ឆេះហើយផ្ទុះដែរ ។

គឺកម្លាំងដែលប្រេងសាំងនឹងខ្យល់ឆេះផ្ទុះនេះហើយដែលជាហេតុនាំឲ្យម៉ាស៊ីនរថយន្តនិងម៉ាស៊ីនយន្តហោះដើរបាន ។

អាទិត្យទី ៤. រៀនសារឡើងវិញ .

---

## ខែមិថុនា

### វត្ថុស្វាធ្យាយន៍

សុំគ្រូបង្រៀនសិស្សសារ ពីដើមឆ្នាំវិញទាំងអស់

មធ្យមដ្ឋានឆ្នាំទី ១

## វិធីបង្ការរោគ

## កាយសិក្សា

១– ឥរិយាបថ – យើងបានដឹងថាឆ្អឹងកូនក្មេងទន់អាចផ្លាស់រាងបានដោយងាយ ៗ ដូច្នេះយើងពុំត្រូវបង្ខំឲ្យក្មេងឆាប់រៀនដើរឡើយ ឆ្អឹងជើងវានឹងកោងជាប់រហូតដោយទម្ងន់ខ្លួនសង្កត់ ៗ

ចូរអ្នកទប់ដំហរឲ្យត្រង់ទោះជាអ្នកអង្គុយឬឈរក៏ដោយ ៗ ឆ្អឹងខ្នងក៏ទន់ណាស់ដែរហើយអាចក្លាយរាងបានដោយងាយ ៗ

ឥរិយាបថមិនល្អបណ្ដាលមិនឲ្យទ្រូងរីកបានដោយលំដាប់តាមទម្លាប់ធម្មជាតិទេ នាំឲ្យការដកដង្ហើមពុំបានស្រួល ដែលជាហេតុនាំឲ្យយើងកើតរបេងបានដោយងាយ ៗ

២ – កាយសិក្សា – ដើម្បីឲ្យមានរាងសមល្មមមានខ្លួនមាំទាំងធ្វើអ្វីបានដោយងាយ អ្នកត្រូវធ្វើសាច់ដុំឲ្យរីកធំឡើង គឺត្រូវឲ្យសាច់ដុំនេះធ្វើការ ៗ មុខនឹងកាយសិក្សាដែលសំខាន់ហើយងាយជាងគេ គឺការដើរទៅកន្លែងណាដែលមានខ្យល់អាកាសល្អ ៗ

ល្បែងគ្រប់យ៉ាងនឹងកីឡា ( ទាត់បាល់, ហែលទឹក, វាយកូនឃ្លី ) ក៏វិសេសដែរតែចូរអ្នកកុំប្រព្រឹត្តល្បែងទាំងនោះឲ្យហួសកំឡាំង ។ ការហាត្ថកម្ម (ជាងឈើ) ការប្បារដំណាំ នាំឲ្យសុខកាយដែរ ។

ចូរអ្នកបំពេញកាយ សិក្សាឲ្យបានតាមរបៀបក្បួនខាតក្នុងមួយថ្ងៃឲ្យបានកន្លះម៉ោង ។

កាយសិក្សានាំឲ្យអ្នកបំភ្លេចការហត់នឿយខាងបញ្ញា នាំឲ្យអ្នកឆ្ងាញ់បាយឲ្យការដកដង្ហើមនិងការឈាមរត់រង្វិលតែបានស្រួលល្អ ។

៣- ការសម្រាក - តែបើអ្នកប្រកាន់ល្បែងកីឡា ឬការហាត់ប្រាណច្រើនហួសពេក សាច់ដុំមិនមែនល្អតលាស់ទេត្រឡប់ជាសឹកទៅវិញ ។ ដូច្នេះចូរអ្នកសំរាកនៅពេលក្រោយអ្នកហាត់រួច ។ ការសម្រាកសំខាន់ជាងគេបំផុតគឺដំណេកនៅពេលយប់ ។ ចូរអ្នកឆាប់អាស្រ័យដំណេកហើយឆាប់ភ្ញាក់ ។ ក្មេងត្រូវអាស្រ័យដំណេកក្នុងមួយថ្ងៃ ១០ ម៉ោងជំទង់ ៩ ម៉ោង-កម្លោះ ៨ម៉ោង ។

---

## ឱសថស្ថាន

### វិធីបង្ការរោគ

រៀនសាឡើងវិញតាំងពីដើមឆ្នាំមក

កុមារដ្ឋាន

## វត្ថុស្វាធ្យាយន៍

អាទិត្យទី ១ និងទី ២    សុំគ្រូសាបស្រៀនពីដើមឆ្នាំមកវិញ អំពីមេរៀនណាដែលសិស្សមិនទាន់យល់ប្រាកដ ៗ

ដូចជាមេរៀនអំពីស្តាំឆ្វេងនឹងឈប់ដើរនៅផ្លូវ គួរតែយកមកបញ្ជាក់ផ្លាថ្មីទៀតវិញពីព្រោះសព្វថ្ងៃនេះ ខ្ញុំបានសង្កេតឃើញក្មេងច្រើន មិនថាតូចមិនថាធំច្រើនធ្វេសប្រហែសស្តាំឆ្វេង បានជាច្រើនមានគ្រោះថ្នាក់តាមផ្លូវជាញយ ៗ ៗ

សុំគ្រូមើលក្នុងទស្សនាវដ្ដីខែកញ្ញា ឆ្នាំ ១៩៥០.១៩៥១.ចុះ

អាទិត្យទី ៣ និងទី ៤ អំពីថ្ងៃខែ នឹងផ្លូវនៅស្រុកខ្មែររៀន មើលប្រក្រតីទិន .

សុំមើលក្នុងទស្សនាវដ្ដីខែតុលា. ឆ្នាំ ១៩៥០ - ៥១

## វិធីបង្ការរោគ

សាបស្រៀនពីដើមឆ្នាំមកវិញក្នុងខែកញ្ញានឹងខែតុលា . ៗ

អំពីការសំអាតខ្លួនប្រាណ - សំអាតសម្លៀកបំពាក់ - បំណីអាហារ - និងប្រើទឹកផ្អិន ។

# បរិច្ឆណភជ្ជាន

## វត្តស្វាធ្យាយន៍

សុំគ្រូសើរើបជ្រៀនតាំងពីដើមឆ្នាំមក ។

អាទិត្យទី ១ អំពីខ្លួនមនុស្ស .- សាច់ដុំ

អាទិត្យទី ២ អំពីការរំលាយអាហារ – ការដកដង្ហើម

អាទិត្យទី ៣ អំពីវិញ្ញាណ ៥– ។

អាទិត្យទី ៤ អំពីច្បាប់ដើរនៅផ្លូវ.

## វិធីបង្ការរោគ

អាទិត្យទី ១ វិធីហាត់ប្រាណ .

អាទិត្យទី ២ ការសំអាតខ្លួនប្រាណ .

អាទិត្យទី ៣ ការថែរក្សាភ្នែក - ត្រចៀក - ធ្មេញនិងសក់

អាទិត្យទី    បញ្ជាក់មេរៀនតាំងពីដើមខែមក

សុំមើលក្នុងទស្សនាវដ្ដីខែកញ្ញានិងតុលាឆ្នាំ ១៩៥០ – ៥១

## លោកនីតិ

សំរាប់មធ្យមដ្ឋានទី ២ និងឧត្តមដ្ឋាន

### មេរៀនទី ១    អំពីរដ្ឋសភា

រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។ រដ្ឋសភាមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ។ ច្បាប់ជាសេចក្ដីសំដែងឆន្ទៈរបស់ប្រជាជាតិ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ បើទោះជាច្បាប់នោះរក្សាការពារក្ដី ផ្ដន្ទាទោសក្ដី បង្ខិតបង្ខំក្ដី ។ គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះរាជអាណាចក្រ ។

អ្នកដែលមានសិទ្ធិផ្ដើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភានិងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។ ច្បាប់ដែលសមាជិកនៃរដ្ឋសភាផ្ដើមគំនិតតែងហៅជាសេចក្ដីព្រាងបញ្ញត្តិ ។ ច្បាប់ដែលគណៈរដ្ឋមន្ត្រីផ្ដើមគំនិតតែង ហៅជាសេចក្ដីស្នើបញ្ញត្តិ ។

សមាជិកទាំងឡាយ នៃរដ្ឋសភាជាអ្នកតំណាងរបស់ប្រជាជាតិទាំង

មូល ពុំមែនត្រឹមតែអ្នកតំណាងរបស់ជនដែលជ្រើសតាំងខ្លួនប៉ុណ្ណោះទេ ។ សមាជិកនៃរដ្ឋសភាមានចំនួន ៨០ រូប តាមច្បាប់ប្រកាសនៅ គ.ស. ១៩៤៧ ដែលស្ដីអំពីការ ជ្រើសតាំងអ្នកតំណាងរាស្ត្រ ។ តាមគោលការណ៍ក្នុងចំនួនបុរសខ្មែរ ១០.០០០ នាក់ដែលមានអាយុ ២១ ឆ្នាំឡើងទៅ ត្រូវមានអ្នកតំណាងមួយរូប ។

អ្នកតំណាងរាស្ត្រត្រូវមានអាយុ ២៥ ឆ្នាំយ៉ាងតិច ហើយនៅក្នុងដំ-ណែងខ្លួនបានតែត្រឹម ៤ ឆ្នាំទេ ។ មុននឹងចូលកាន់ដំណែងសមាជិកនៃរដ្ឋសភាត្រូវតាំងសច្ចាប្រណិធានក្នុងទីប្រជុំចំពោះ ព្រះភក្ត្រព្រះមហា-ក្សត្រិយ៍ថាមានចិត្តស្មោះត្រង់ចំពោះព្រះភក្ត្រព្រះមហាក្សត្រិយ៍ ថាមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ហើយនឹងរដ្ឋធម្មនុញ្ញ ។

អ្នកដំណាងរាស្ត្រមិនអាចត្រូវចោទប្រកាន់រកខ្លួនចាប់ខ្លួនឃុំឃាំងឬជំនុំជំរះ ក្នុងពេលដែលថិតក្នុងសមាជិកភាពទេ វៀរលែងតែអ្នកដំណាងរាស្ត្រនោះបានប្រព្រឹត្តបទល្មើស ដែលបានទាន់ឃើញជាក់ស្ដែង ។

រដ្ឋសភាមានសម័យប្រជុំសាមញ្ញយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ។ សម័យប្រជុំនីមួយ ៗ មានកំណត់យ៉ាងតិចបីខែ ។ ក្នុងសម័យប្រជុំសា-មញ្ញពីរនេះ សម័យប្រជុំមួយត្រូវចាប់ផ្ដើមក្នុងខែកញ្ញា ។

ព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់ហៅរដ្ឋសភាប្រជុំជាសម័យប្រជុំសា-

មញ្ញ ។ ក្រុមអភិបាលរដ្ឋសភាជាអ្នកហៅសមាជិកប្រជុំ ជាសម័យប្រជុំវិសាមញ្ញដោយបានទទួលព្រះរាជបញ្ញត្តិ ដោយសេចក្ដីណែនាំនៃគណៈរដ្ឋមន្ត្រីក្ដី ឬដោយសេចក្ដីសុំរបស់ភាគ ១ ក្នុងភាគបី (១/៣) យ៉ាងតិចនៃចំនួនអ្នកតំណាងរាស្ត្រទាំងពួងក្ដី ។ របៀបវារៈនៃសម័យប្រជុំវិសាមញ្ញនេះត្រូវផ្សាយដល់មហាជនព្រមជាមួយនឹងថ្ងៃណាត់ប្រជុំ ។ សេចក្ដីកត់ហេតុនៃសម័យប្រជុំនោះត្រូវចុះផ្សាយក្នុងរាជកិច្ចផង ។

## មេរៀនទី២.– អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ

ក្រុមប្រឹក្សាព្រះរាជអាណាចក្រនឹងរដ្ឋសភារួមគ្នាហៅថាសភា ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ គ្មានសិទ្ធិបញ្ចេញមតិតាំងច្បាប់ទេ ហើយកាន់អំណាចតិចជាងរដ្ឋសភាផង ។ គណៈរដ្ឋមន្ត្រីមិនទទួលខុសត្រូវចំពោះក្រុមប្រឹក្សាព្រះរាជអាណាចក្រទេ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មានសមាជិកចំនួន ២៤ រូប ។ សមាជិកខ្លះត្រូវចាត់តាំង ខ្លះត្រូវជ្រើសតាំងដោយបោះឆ្នោតអសាកល ។ សមាជិកទាំងនោះ ត្រូវមានអាយុ ៤០ ឆ្នាំយ៉ាងតិច ។ អាណត្តិនៃទីប្រឹក្សាព្រះរាជអាណាចក្រ មានកំណត់បួនឆ្នាំហើយទីប្រឹក្សា ព្រះរាជអាណាចក្រ ត្រូវហៅប្រជុំហើយត្រូវប្រជុំក្នុងពេលជាមួយគ្នា នឹងរដ្ឋសភា ។

ក្នុងមួយឆ្នាំ ៗ ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ជ្រើសតាំងប៊ុយរ៉ូនៃគណៈកម្មការនានារបស់ខ្លួនដូចរដ្ឋសភាដែរ ។

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ពិនិត្យហើយឲ្យយោបល់អំពីសេចក្តីព្រាងនិងសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយ ព្រមទាំងអំពីបញ្ហាទាំងពួង ដែលរដ្ឋាភិបាលបានដាក់ឲ្យពិនិត្យ ។

អំពីសេចក្តីព្រាងនិងសេចក្តីស្នើច្បាប់ ហើយនិងអំពីច្បាប់ថវិកា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវឲ្យយោបល់ កំណត់មួយខែយ៉ាងយូរ ។ បើជាការប្រញាប់កំណត់វេលានោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ បានឲ្យយោបល់យល់ព្រមឬពុំបានឲ្យយោបល់សោះ ក្នុងវេលាដែលមានកំណត់ទុកហើយ នោះច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រម ហើយនោះត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។ បើជាការប្រញាប់កំណត់វេលានោះ ត្រូវបន្ថយមកនៅត្រឹមតែពីរថ្ងៃ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ សូមឲ្យកែសម្រួលសេចក្តីព្រាង

ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាម ជាលើកទី ២ ។

បើក្រុមប្រឹក្សាព្រះរាជអាណាចក្រ បដិសេធសេចក្តីព្រាងឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាមិនអាចយកមកពិចារណា ជាលើកទី ២ មុនកំណត់ពេលមួយខែទេ ។

ការពិនិត្យសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវបញ្ចេញមតិ ដោយវិធីបោះឆ្នោត ចំហយកតាមភាគច្រើនដោយដាច់ខាតនៃសមាជិករដ្ឋសភា ។ សេចក្តីព្រាងឬសេចក្តីស្នើច្បាប់ណាដែលបានធ្វើសម្រេចដូចខាងលើនេះ ហើយត្រូវប្រកាសឲ្យប្រើក្នុងកំណត់ដប់ថ្ងៃ ។

## អំពីរបៀបជ្រើសតាំងតំណាងរាស្ត្រ

ក្នុងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ បណ្តាជនទាំងអស់ជួយចាត់ចែងការគ្រប់គ្រងប្រទេសខ្លួន ប៉ុន្តែមិនមែនចាត់ចែងដោយចំពោះទេ គឺតាមរយៈនៃអ្នកតំណាងខ្លួន ។

ក្នុងសម័យបោះឆ្នោតមានបេក្ខជនជាច្រើន ឈរឈ្មោះឲ្យគេជ្រើសតាំងជាអ្នកតំណាងរាស្ត្រ ។ បុរសដែលមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រទាំងឡាយ ក៏បោះឆ្នោតឲ្យឈ្មោះបេក្ខជនណាមួយដែលគាប់ចិត្ត

ខ្លួន ៗ បោះឆ្នោតគឺយល់ព្រមទទួលយកឬ មិនយល់ព្រមទទួលយកបេក្ខជនណាមួយធ្វើជាអ្នកតំណាងខ្លួន ។

អធិបតេយ្យនៃបណ្ដាជនទាំងឡាយ នឹងអាចប្រព្រឹត្តទៅបានដោយសារការជ្រើសតាំងអ្នកតំណាងនេះ ដ្បិតអ្នកតំណាងនេះហើយ ដែលជាអ្នកសម្រេចការផ្សេង ៗ នឹងចាត់ចែងកិច្ចការនានា ក្នុងការគ្រប់គ្រងប្រទេសព្រមទាំងជាអ្នកតែងច្បាប់ក្នុងនាមបណ្ដាជនផង ។

ការបោះឆ្នោតជាការមួយសំខាន់ណាស់ចំពោះប្រទេស ពីព្រោះជោគវាសនារបស់ប្រទេស ឋិតនៅកណ្ដាប់ដៃនៃអ្នកតំណាងរាស្ត្រ ។ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បើកឲ្យប្រុសខ្មែរទាំងអស់មានសិទ្ធិជ្រើសតាំងអ្នកតំណាងដូច្នេះបណ្ដាជនទាំងឡាយ ត្រូវប្រើសិទ្ធិនេះឲ្យពេញលេញ ។ មិនបញ្ចេញមតិជ្រើសតាំងគឺលះបង់ចោលអំណាចដែលខ្លួនមាន ដើម្បីជួយជ្រោមជ្រែងរបៀបចាត់ចែងការគ្រប់គ្រងប្រទេស ។ ជ្រើសតាំងដោយទុច្ចុក គឺប្រទានប្រទេសទាំងមូលទៅក្នុងភយន្តរាយផ្សេង ៗ ។

ហេតុនេះពលរដ្ឋម្នាក់ ៗ មានករណីយកិច្ច នឹងជ្រើសតាំងអ្នកតំណាងខ្លួនឲ្យត្រឹមត្រូវគឺថា ៖ ជ្រើសតាំងដោយឥតទាក់ទិន នឹងលាភឬផលប្រយោជន៍ទេ ដោយឯកច្ឆានចិត្តឥតមានអ្នកឯណាបង្ខិតបង្ខំ គឺជ្រើសតាំងតាមសម្បជញ្ញៈខ្លួន ។

ត្រូវបោះឆ្នោតឲ្យបេក្ខជនណាដែលយើងជឿជាក់ថា មានសមត្ថភាពនឹងធ្វើការឲ្យប្រទេសបាន ។

---

មេរៀនត្រូវចាំមាត់

(សំរាប់គ្រប់ថ្នាក់)

## ១ – ស្តាំ-ឆ្វេង

ជិះទូកកម្ចាល់ ត្រូវតែឲ្យស្គាល់ ឲ្យយល់ឆ្វេងស្តាំ
ដោយដៃទាំងពីរ ជាទីចំណាំ មានឆ្វេងមានស្តាំ
អាចនាំឲ្យក្សាន្ត ។ ទោះដើរឬជិះ រថយន្តឬសេះ
ទោចក្រយាន ឬយានត្រីចក្រ លើថ្នល់សព្វឋាន
ចូរចាំឲ្យបាន ខាងស្តាំកុំភ្លេច ។ កុំភ្ញាក់ឲ្យសោះ
ក្រែងលោមានគ្រោះ ដល់ប៉ះទង្គិច បើចាំខាងស្តាំ
ចំណាំកុំភ្លេច ចង្កៀតដូចម្តេច ទង្គិចមិនបាន ។
កុមារទាំងឡាយ យាត្រាជិតឆ្ងាយ អ្នកសុខក្សេមក្សាន្ត

ដោយអ្នកប្រកាន់ ខាងស្តាំឲ្យបាន ទោះអ្នកជិះយាន
ក៏គ្មានសៅហ្មង ៗ លើចិញ្ចើមថ្នល់ ៗ ឥតមានអំពល់
នឹងដើរកាត់ថ្នង មិនបានប្រកាន់ ស្តាំឆ្វេងទេហោង
ខុសត្រូវទំនង បែបណាក៏ដោយ ៗ

ពាក្យពន្យល់.— ក្សាន្ត = សុខស្រួល ៗ រថយន្ត: ឡាន
ទោចក្រយាន – រទេះកង់ ៗ យានត្រីចក្រឬ
ត្រីចក្រយាន – ស៊ីក្លូ ៗ យាត្រា = ដើរ ៗ

---

## ២– ភ្លៀង

ពេលចំហាយក្តៅ ស្ងប់ស្រៀបស្ងូន្យទៅ មានខ្យល់ត្រជាក់
មកពីនិរតី ពពកខ្មៅធ្លាក់ រសាត់ប្រត្យក្ស
ដោយសារតែខ្យល់ ៗ លុះខ្យល់ត្រជាក់ ពពកព័ទ្ធពាក់
បក់ផ្គុំប្របល់ មេឃមីរស្រទំ មួយរំពេចដល់
ដំណក់ទឹកជល ធ្លាក់មកគឺភ្លៀង ៗ ជួនកាលភ្លៀងខ្លាំង
ផ្លេកបន្ទោរចាំង មានព្យុះសូរសៀង ផ្គរលាន់សន្ធាប់
កណ្តាលគ្រាប់ភ្លៀង ជួនព្យុះសំនៀង រន្ទះខ្លាំងក្រៃ ៗ
នៅគ្រប់ទីឋាន ពេលដែលភ្លៀងមាន អ្នកស្រុកប្រុសស្រី

សាសំពត់អាវ ដែលនៅហាលថ្ងៃ វត្ថុអ្វីក្តី

ភ័យខ្លាចទទឹក ៗ អ្នកក្រអ្នកកាស់ អ្នកសួនទាំងអស់

ឥតមាននាទឹក ទោះភ្លៀងយ៉ាងណា ឥតខ្លាចទទឹក

គ្មានគិតរវើក គ្មានក្តីរអែង ៗ

ពាក្យពន្យល់ - ប្រៀប = ដែលស្ទាត់ឈឹងឥតមានពុស្សូរ

ស័ត្វអ្វី ៗ ប្រត្យក្ស = (ម.ថ-ប្រ-យ័ត)

ប្រាកដ ៗ ជល = (ម.ថ ជល់) ទឹក ៗ

មីរ = (គ,) ទូទឹមឈ្លប់ ៗ សៀង=សំឡេង ៗ

---

## ៣.– ព្រះចន្ទ

ព្រះចន្ទមានសណ្ឋាន មូលតែគ្មានពន្លឺទេ

អណ្តែតដូចស្បូវដែរ តាមអាកាសវេហាស៍ ៗ

រស្មីនៃព្រះចន្ទ ទទួលកាន់ពីសុរិយា

ទើបផ្សាយនូវបកា ដល់បជាគីយើងផង ៗ

ហេតុនេះហើយបានជា ចន្ទាកាខ្សោយកន្ទង

ត្រជាក់ពិតតែម្តង ជាងពន្លឺព្រះសុរិយា ៗ

ព្រះចន្ទវិលក្រឡឹង   បឋវីអស់ទិសា

សាមសិបសាមមួយណា   គេហៅថាពេញ ១ ខែ ។

ពាក្យពន្យល់ ៖— សូរ្យ = (ម.ថ សូ) មកពីពាក្យថាសុរិយៈព្រះអាទិត្យ ។ វេហាស៍ៈ (ម.ថ ហ៊ា) ប្រទេសជាទីគពយនៃសត្វស្លាបបានដល់អាកាស, មេឃ ។ សុរិយា = ព្រះអាទិត្យ ។ បភា = (ម.ថ ប៉ៈភា) ពន្លឺ ។ បជា — (ម.ថ ប៉ៈជា) ពពួកមនុស្សសត្វ ។ ចន្ទាភា (ម,ថ ច័ន-ទា-ភា) ពន្លឺរស្មីនៃព្រះចន្ទ ។ បឋវី = ( ម ថ វឹង ) នូវផែនដី ។ ទិវសា = ថ្ងៃ ។

---

## ៤- ភ្ជុំបិណ្ឌ

ស្រុកខ្មែរមានបុណ្យធំ   គឺបិណ្ឌភ្ជុំបុណ្យបូលឆ្នាំ
ហើយទឹកចិនកម្ម   គេចំណាំតាមសាសនា ។
ឯបុណ្យភ្ជុំបិណ្ឌអស់   អ្នកស្រុកប្រុសស្រីគ្រប់គ្នា
គាន់យកបារីស្វា   ភោជន៍អាហារជុំក្នុងវត្ត ។
លុះជុំគ្នាកាលណា   នមស្សការព្រះត្រៃរ័តន៍
ហើយក៏ប្រគេនភត្ត   គឺយាគុក្នុងពេលព្រឹក ។
ព្រះសង្ឃឆាន់កាលណា   លោកអនុមោទនាសូរគ្រឹក
ស្រេចកិច្ចក្នុងពេលព្រឹក   លុះដល់ពេលជិតថ្ងៃត្រង់ ។

អ្នកស្រុកប្រជុំគ្នា　　វេរអាហារចំពោះសង្ឃ
ដែលមកប្រជុំគន់　　ក្នុងសាលាបុណ្យធំនោះ ។
វេរហើយលោកកត្តា　　សូត្រធម៌ផារគ្រប់អង្គស្មោះ
បង្សុកូលក្នុងពេលនោះ　　ទើបស្រីប្រុសយក្កិញផ្កាយ ។
ភាគផលដល់មាតា　　នឹងបិតាបុត្រទាំងឡាយ
ដែលស្លាប់កន្លងឆ្ងាយ　　គ្រប់រូបកាយឥតសេសសល់ ។

ពាក្យពន្យល់.- ភោជនៈ ( ម.ថភោជ ) ភោជន ។

នមស្ការៈ សូត្រធម៌ថ្វាយបង្គំ ។
ត្រៃរ័តន៍ = ( ម.ថ រ័ត ) គឺរតនត្រ័យ ។
យាគុ = បបរ ។ កត្តា= មកពីពាក្យថាកត្តានុមោទនាគឺអនុ
មោទនាកត្ត ។ ផារ =(ម.ថ.ផា) មកពីពាក្យតារ= ការ
ជូន ។ បង្សុកូល = (ម.ថ.សុ-កូល)
និយាយក្លាយថាប័ងស្កូល ។

## ៥- បុណ្យខ្មោច

មនុស្សអនិច្ចកម្ម　　តាមចំណាំចាស់ព្រឹទ្ធា
បំអាសទឹកកាលណា　　ទើបគេយកសំពត់គ្រប ។

និមន្តលោកបង្សុកូល ហើយគេលើកព្រមទាំងស្នប
ដាក់ក្នុងមឈូសគ្រប និមន្តលោកបង្សុកូលទៀត ។
បើគេដំកល់យូរ តែងគិតគូរគំនិតឆ្លៀត
បង្សុកូលច្រើនដងទៀត ព្រមទាំងសូត្រព្រះធម៌ថ្ងៃ ។
ឯបុត្រភរិយាខ្មោច ញាតិពង្សពូជទាំងប្រុសស្រី
ទាំងតូចទាំងធំក្ដី កោរកេសីស្លៀកពាក់ស ។
មុនពេលហែសពចេញ ពីផ្ទះវិញលោកទៅឈរ
សូត្រធម៌ដំបូរ គឺបង្សុកូលរំកិលសព ។
លុះពេលហែចេញទៅ គឺគេត្រូវធ្វើបែបគ្រប់
ដើរអមមុខក្រោយសព លោកប្រាំអង្គគង់ស្វាធ្យាយ ។
មួយអង្គសូត្រអភិធម្ម បួនអង្គអមសពមិនឆ្ងាយ
ទ្រង់តាំងហឫទ័យផ្សាយ ចំពោះសពសូត្រមាតិកា ។
លុះហែខ្មោចទៅដល់ ប្រទក្សិណទីបាឆា
ដាក់លើជើងថ្កណា មុនបូជាបង្សុកូលទៀត ។

ពាក្យពន្យល់–. អនិច្ចកម្ម = ស្លាប់ ។ ព្រឹទ្ធា = ចាស់ពីបូរាណ ។

ចំអាស: = ខាងជំរះរូបអសុភដែលទើបនឹង

ស្លាប់ ។ ស្នបៈសំពត់សដែលរុំរូបខ្មោច ។

មញ្ជូស= ការមានសណ្ឋានជាហិបសំរាប់ដាក់សាកសពមនុស្ស ។ កេសី, សក់ ។ បវរៈ (ម. ថ. វ៉ឺ) ប្រសើរ ។ ស្វាធ្យាយៈសូត្រ ។ អភិធម្ម = (ម. ថ. ធ័ម) ធម៌ក្រៃលែង, ធម៌ល្អិត ។

## ៦- ពេលឈប់សម្រាករៀន

កូនសិស្សរៀនសូត្រវិទ្យាសាស្ត្រ ច្រើនណាស់នាំឲ្យវិឃ្សិការណ៍
ពេលឈប់សម្រាករៀនសិក្សា រាជការកំណត់ពីរខែពិត ។
ដើម្បីលំហែលំហើយកាយ សប្បាយរីករាយផ្លូវគំនិត
វិស្សមកាលមានកំរិត គិតពីដប់បួនកក្កដា ។
រៀងរាបដរាបអន្លូងក្រែ ដល់ថ្ងៃដប់មួយខែកញ្ញា
សម្រាកវិហាររយាត្រា ទៅកាន់គ្រឹះឋានខ្លួនទីទៃ ។
ដើម្បីសក្ការសម្មាន សន្តានព្រៀងលានឯនាយនៃ
ជួយធ្វើការងារកិច្ចប្រពៃ ក្ខួរដើដកស្ទូងតាមធម្មតា ។
ខ្លះក៏មិនទៅនៅចំពេញ ចំរៀនទន្ទេញតាមប្រាថ្នា
ផុតពេលទំនេរទ្វេមាសា ចូលកាន់សាលាធម្មតាវិញ ។
ជួបជុំកូនសិស្សទាំងប៉ុន្មាន មកពីគ្រឹះស្ថានមូលពាសពេញ

ចាប់រៀនសិក្សាសូត្រទន្ទេញ    បំពេញវិទ្យាជានិរន្តរ៍ ។

ពាក្យពន្យល់ - វិទ្យាសាស្ត្រៈគម្ពីរប្រាប់វិជ្ជាផ្សេង ៗ ។

វឌ្ឍិការណ៍ = ហេតុដែលនាំឲ្យមានសេចក្ដីចំរើន ។

វិស្សមមាស : ( ម.ថ វិស្សៈ-មៈ-មាសៈ )

សម្រាករៀន ។ វិហារយាត្រា: ( វិហារៈយាត្រា )

ការដើរលេងសប្បាយ ។

សក្ការសម្មាន : ( ម.ថ សក្ការៈសៈម៉ានៈ ) សេចក្ដីរាប់អាន, សេចក្ដីគួរសម ។ ទ្វេមាសា = ( ម.ថ ទ្វេ = ពីរ ) ពីខែ ។ និរន្តរ៍ = ( ម.ថ និរន់ដរ ) ដែលឥតមានចន្លោះ, រកពេលគ្មាន ។

---

រោងពុម្ពខ្មែរ